គម្រោងបង្ហាញបច្ចេកវិទ្យាដើម្បីបង្កើនផលិតភាពជុំវិញតំបន់ទន្លេសាប

(ADB TA 7305-CAM)





# ឯកសារបណ្តុះបណ្តាល

## ស្តីអំពី

# ការពង្រឹងសមត្ថភាពក្រុមកសិករផលិត និង ជំនួញស្រូវពូជ



**វិច្ឆិកា ២០១១**

(DRAFT)

# មាតិកា

| ល.រ | មាតិកា | ទំព័រ |
|---|---|---|
| | **អារម្ភកថា** | ២ |
| ១ | ការបង្កើត និង កសាងក្រុម | ៣ |
| ២ | ការប្រាស្រ័យទាក់ទង | ៩ |
| ៣ | ការរៀបចំអង្គប្រជុំ | ១៣ |
| ៤ | ការសរសេ របាយការណ៍ និង កំណត់ហេតុ | ១៥ |
| ៥ | ការគ្រប់គ្រង និងភាពជាអ្នកដឹកនាំ | ២០ |
| ៦ | ការគ្រប់គ្រងហិរញ្ញវត្ថុរបស់ក្រុម | ២៥ |
| ៧ | មូលដ្ឋានគ្រឹះទីផ្សារ | ២៩ |
| ៨ | ការចាប់ផ្តើមអាជីវកម្ម | ៣២ |
| ៩ | ការគ្រប់គ្រងអាជីវកម្ម | ៣៦ |
| ១០ | ការលើកកំពស់អាជីវកម្ម | ៤០ |
| ១១ | និរន្តរភាពអាជីវកម្ម | ៤៣ |

**ឯកសារយោង**


1. ការគ្រប់គ្រងសមាគមអាជីវកម្មធុនតូច រៀបចំដោយ អង្គការពលកម្មអន្តរជាតិ ឆ្នាំ ២០០៧
2. សៀវភៅមគ្គុទេសបណ្តុះបណ្តាលគ្រូបង្គោលសំរាប់ការអភិវឌ្ឍន៍ រៀបចំដោយអង្គការល្ងថេរ៉ាន បំរើពិភពលោក ឆ្នាំ ២០០៥
3. ចាប់ផ្តើម និង ការកែលំអរអាជីវកម្មរបស់អ្នករៀបចំអង្គការល្ងថេរ៉ានបំរើពិភពលោក ឆ្នាំ ២០០៧
4. អង្គការ FAO សៀវភៅធនធានសម្រាប់អន្តរក្រុមៈ ការណែនាំសម្រាប់បង្កើតសមាគមកសិករតូចៗ និងបណ្តាញការងារ

# អារម្ភកថា

គម្រោងបង្ហាញបច្ចេកវិទ្យា ដើម្បីបង្កើនផលិតភាពជុំវិញតំបន់ទន្លេសាប (TSTD) ជាគម្រោងជំនួយបច្ចេកទេសដែលផ្ដល់សហ–ហិរញ្ញប្បទានឥតសំណង សម្រាប់អនុវត្តដោយ រដ្ឋាភិបាលហ្វាំងឡង់ មូលនិធិជែគូអ៊ី–អាស៊ី និងចែករំលែកពុទ្ធិនៃសាធារណៈរដ្ឋកូរ៉េ និង ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ។ រាជរដ្ឋាភិបាលកម្ពុជាចូលរួមបដិភាគមិនមែនជាថវិកា (ធនធានមនុស្ស ការិយាល័យបំពេញការងារ...) សម្រាប់អនុវត្តគម្រោង។ ធនាគារអភិវឌ្ឍន៍អាស៊ី ជាអ្នកចាត់ចែងប្រតិបត្តិការផ្ទាល់ជំនួសមុខឱ្យម្ចាស់ជំនួយ។ គម្រោង បានធ្វើការសាកល្បងបង្ហាញបច្ចេកវិទ្យាកសិកម្ម និង ផ្ដល់សេវាព័ត៌មានជនបទ ដើម្បីបង្កើន និងពង្រីកប្រាក់ចំណូលរបស់គ្រួសារកសិករខ្នាតតូចក្នុងខេត្ត កំពង់ចាម កំពង់ធំ សៀមរាប និង បន្ទាយមានជ័យ។

ឯកសារបណ្ដុះបណ្ដាលស្ដីពី *ការពង្រឹងក្រុមកសិករផលិតស្រូវពូជលក់* នេះត្រូវបានរៀបចំចងក្រងឡើងដោយផ្អែកលើឯកសារយោងនានា ព្រមទាំងបទពិសោធន៍ល្អជាក់ស្ដែងរបស់អ្នកអនុវត្តផ្ទាល់ ក្នុងគោលបំណងចងក្រងជាបង្គុំឯកសារជំនួយស្មារតី និងពង្រឹងនូវសមត្ថភាពដល់ក្រុមកសិករអាជីវកម្ម នៅតាមសហគមន៍ឱ្យទទួលបាននូវគំនិតសម្រាប់អភិវឌ្ឍន៍អាជីវកម្មរបស់ពួកគាត់ ឱ្យកាន់តែប្រសើរឡើង។ ការធ្វើអាជីវកម្មជាក្រុមនៅតាមជនបទឱ្យទទួលបានជោគជ័យ គឺជាកិច្ចការមួយលំបាក ដោយសារស្ថានភាពរស់នៅ ចំណេះដឹង និងបទពិសោធន៍នៃការរកស៊ីរួមគ្នា របស់កសិករនាពេលបច្ចុប្បន្ននៅមានកំរិតនៅឡើយ។ ឯកសារនេះ ត្រូវបានរៀបចំឡើងដើម្បីជួយសម្រួលកិច្ចដំណើរការ និងគ្រប់គ្រងក្រុមមានប្រសិទ្ធភាព តាមរយៈការកសាងសមត្ថភាពសមាជិកក្រុម លើផ្នែក កសាងក្រុម ការប្រាស្រ័យទាក់ទង ការដឹកនាំក្រុម ក៏ដូចជាស្ដីពី គោលគំនិតគ្រឹះនៃការចាប់ផ្ដើម និងគ្រប់គ្រងអាជីវកម្មជាក្រុម។ វាក៏អាចជា ឯកសារប្រឹក្សាយោបល់ស្ដីពី កិច្ចការជំនួញរបស់ក្រុមកសិករដែលចាប់ផ្ដើមអាជីវកម្មរួមគ្នា នៅតាមជនបទ។

យើងខ្ញុំសូមស្វាគមន៍ចំពោះការកែលម្អ និង ការផ្ដល់យោបល់នានាដើម្បីជាកិច្ចខិតខំប្រឹងប្រែងក្នុងការពង្រឹងនូវគុណភាពនៃឯកសារ នេះក្នុងគោលបំណងចូលរួមចំណែកអភិវឌ្ឍន៍ប្រទេសជាតិ តាមរយៈការអភិវឌ្ឍន៍ធនធានមនុស្សនៅកម្ពុជា ជាពិសេស កសិករនៅតាមជនបទ។

ការអនុវត្តន៍កម្មវិធីធ្វើបង្ហាញ ស្ដីពី *ផលិតកម្មពូជស្រូវសម្រាប់លក់ជាក្រុម* នេះ អាចដំណើរការបានដោយសារមានការគាំទ្រពីថ្នាក់ដឹកនាំគម្រោង និង ក្រុមទីប្រឹក្សាគម្រោង TSTD និង ពីមន្ទីរកសិកម្មខេត្ត ទាំងបួន។

**អ្នករៀបរៀង:**

**លោក សំ សំណាង** អ្នកជំនាញផ្នែកក្សេត្រសាស្ត្រ / បន្លែ របស់គម្រោង TSTD

អ៊ីម៉ែល : Samnang_news@yahoo.com

**កែសម្រួលដោយ**

**លោក លីវ លាងហ៊ី** អ្នកជំនាញផ្នែកផ្សព្វផ្សាយ និងបច្ចេកវិទ្យារបស់គម្រោង TSTD

អ៊ីម៉ែល: livleanghy@gmail.com

# មេរៀនទី១ ការបង្កើត និង កសាងក្រុមការងារ

## ១. សេចក្តីផ្តើម

ជាទូទៅក្រុមការងារ ឬ ក្រុមសហគមន៍មូលដ្ឋានមួយ ត្រូវបានរៀបចំឡើង តាមរយៈការប្រជុំឯកភាពគ្នា ក្រោមគំនិតផ្តួចផ្តើមដោយសហគមន៍ផ្ទាល់ ឬ ក្រុមការងារ ដែលមានបំណងចូលរួមនៅក្នុងការងារអភិវឌ្ឍន៍ ឬក៏ដោយអាជ្ញាធរដែនដី។ ដើម្បីផ្តល់ភាពងាយស្រួលដល់ការអនុវត្តន៍ការងារ និង ជាប្រយោជន៍ដល់ការបង្កើតក្រុមឱ្យក្លាយជាក្រុមស្របច្បាប់នោះ ការរៀចចំរចនាសម្ព័ន្ធ គឺជាជំហានសំខាន់បំផុត នៅក្នុងដំណើរការគ្រប់គ្រង និង ការងារជាក្រុម។

នៅក្នុងការរៀបចំរចនាសម្ព័នក្រុមនេះ មានវិធីជាច្រើនដែលបានប្រើដូចជា ការចាត់តាំង,ការបោះឆ្នោត និង ការស្ម័គ្រចិត្ត ជាដើម។ ប៉ុន្តែនៅប៉ុន្មានទស្សវត្សចុងក្រោយនេះ ការរៀបចំរចនាសម្ព័ន្ធរយៈការបោះឆ្នោត ជាវិធី មានប្រជាប្រិយ និង មានប្រសិទ្ធភាព ដែលត្រូវបានគេប្រើ។

ក្រោយពីការបោះឆ្នោតជ្រើសតាំងរចនាសម្ព័ន្ធរួចហើយ ជាទូទៅ ការទទួលស្គាល់ ពីអាជ្ញាធរដែនដី ដូចជា ឃុំ និង មន្ទីរពាក់ព័ន្ធ ជាកត្តាចាំបាច់មួយ ដែលធ្វើឱ្យក្រុមក្លាយទៅជាក្រុមស្របច្បាប់នៅក្នុងកំរិតថ្នាក់មូលដ្ឋាន។

ការបង្កើតក្រុម អាចសំរេចបានដោយងាយស្រួល បើមានការគាំទ្រពីសំណាក់អាជ្ញាធរ ប៉ុន្តែប្រការដែលលំបាកគឺការថែរក្សា និង ជំរុញឱ្យក្រុមនេះក្លាយជាក្រុម ដែលមានសក្តានុពល និង រឹងមាំ និង មាននិរន្តភាពលើការងារ ។ យន្តការជាច្រើនត្រូវបានធ្វើឡើង ដូចជាការរៀបចំតួនាទីភារកិច្ច ការពង្រឹងសមត្ថភាព ការគាំទ្រទាំងស្មារតី និង ថវិកា...... ជាដើម។ បទពិសោធន៍ជាច្រើនត្រូវបានបង្ហាញ និង លើកឡើង ដើម្បីជាការរៀនសូត្រនៅក្នុងការពង្រឹងក្រុមការងារនេះ។

ដើម្បីឱ្យកាន់តែយល់ច្បាស់ និង ចូលរួមចំណែកនៅក្នុងការពង្រឹងសមត្ថភាពក្រុមសហគមន៍មូលដ្ឋាន មេរៀននេះ នឹងជួយមួយចំណែកដល់ការបង្កើននូវសន្ទុះការងាររបស់ក្រុម។

## ២. និយមន័យក្រុម

- **ក្រុម (Group) :** ជា *ទំនាក់ទំនងបឋម* (រវាងបុគ្គល) សំដៅចែកចាយពត៌មាន និងធ្វើការសំរេចចិត្ត ដើម្បីជួយដល់មនុស្សម្នាក់ៗ ឱ្យអនុវត្តការងារទៅតាមភារៈកិច្ចទទួលខុសត្រូវរបស់គេ ដាច់ដោយឡែករៀងៗខ្លួន។

- **ក្រុមការងារ (Team):** គឺជាក្រុមមនុស្ស ដែលសមាជិកបុគ្គលិកម្នាក់ៗខិតខំប្រឹងប្រែងរួមគ្នាដើម្បីសំរេចលទ្ធផលការងារ បានល្អប្រសើរ ជាជាងគ្រាន់តែទាក់ទងស្វែងរកការចូលរួមយោបល់ពីបុគ្គលិកម្នាក់ៗ។

# ជំហាននានាក្នុងការបង្កើតក្រុម


បង្កើតការយល់ដឹង


កំណត់សមាជិកភាព


រៀបចំប្រជុំលើកដំបូង


កំណត់គោលបំណង


សំរេចការងារធ្វើជាបុគ្គល និងការងាររួមគ្នា
និងបែងចែកការងារ



រៀបចំវិន័យ


ជ្រើសរើសអ្នកដឹកនាំ



ធ្វើផែនការអាជីវកម្ម


សំរេចលើការចាត់ចែងហិរញ្ញវត្ថុ



ក្រុម (group)



ក្រុមការងារ (team)

| ក្រុម (group) | | ក្រុមការងារ (team) |
|---|---|---|
| ចែកចាយពត៌មាន | គោលបំណង | អនុវត្តការងាររួមគ្នា |
| បុគ្គលម្នាក់ៗ | ភាពទទួលខុសត្រូវ | បុគ្គលម្នាក់ៗ និងជួយគ្នាទៅវិញទៅមក |
| យុទ្ធសាស្ត្រ និងលក្ខណៈ ផ្សេងៗគ្នា | ជំនាញ | លក្ខណៈគ្រប់គ្រាន់បំពេញឱ្យគ្នា |

## ៣. ហេតុអ្វីបានជាធ្វើការងារជាក្រុម ?

- **ក្រុមផ្តល់ការគាំទ្រ:** ពួកគេមិនអាចធ្វើការតែម្នាក់ឯង ហើយទទួលភារៈកិច្ចទាំងអស់បានទេ ប៉ុន្តែក្រុមអាចក្លាយទៅជាធនធានមួយសម្រាប់គាំទ្រ និងលើកទឹកចិត្តគ្នា។ ភាពប្រឈមមុខ និងភាពតានតឹង អាចនាំឱ្យមានបន្ទុកធ្ងន់ និង មានការទាមទារខ្លាំងទៅលើការងារ ដែលអាចធ្វើឱ្យមនុស្សបោះបង់ចោលនូវការយល់ចិត្តជាមួយអ្នក ដូច្នេះអ្នកគួរតែរួបរួមគ្នា ដើម្បីដោះស្រាយវា។
- **ក្រុមអាចជួយដោះស្រាយភាពស្មុគ្រស្មាញ បានល្អ:** ការធ្វើការងាររួមគ្នាអាចឱ្យយើងផ្លាស់ប្តូរការងារស្មុគ្រស្មាញ ឬ លំបាក ទៅជាភាពងាយស្រួល ធ្វើឱ្យការងារអាចគ្រប់គ្រងបាន ។ គ្មាននរណាដែលមានការលំបាក ឬ ទទួលបន្ទុកភារៈកិច្ចការធ្ងន់ម្នាក់ឯង ដែលធ្វើឱ្យមានភាពស្មុគ្រស្មាញទៅដល់សកម្មភាពផ្ទាល់ខ្លួនរបស់ពួកគេទេ។ ដូច្នេះ ការចែករំលែកសកម្មភាពរួមគ្នាត្រូវកាត់បន្ថយភាពស្មុគ្រស្មាញ។
- **ក្រុមការងារអាចមានទំនោរទៅរកភាពច្នៃប្រឌិត និងផលិតភាពខ្ពស់:** គំនិតយោបល់ល្អៗជាច្រើនដែលបានបញ្ចូលនូវរបៀបថ្មី គឺជាលទ្ធផលបានមកពីការប្រមូលផ្តុំគំនិតទាំងអស់ ដែលទទួលបានពីបុគ្គលនិមួយៗ។ លក្ខណៈសំបូរបែបផ្សេងៗគ្នា នៃប្រវត្តិចំណេះដឹងផ្សេងៗ ជំនាញផ្សេងៗ និងបទពិសោធន៍ផ្សេងៗ អាចនាំមកនូវគំនិតច្នៃប្រឌិត និង ផលិតភាពខ្ពស់ក្នុងក្រុមការងារ។
- **ក្រុមការងារជាធម្មតាតែងតែនាំមកនូវដំណោះស្រាយមួយដ៏ល្អ:** ការសំរេចចិត្តមួយដ៏ល្អ រឺ ការដោះស្រាយបញ្ហាយ៉ាងសមរម្យ គឺតែងតែកើតឡើងតាមរយៈក្រុមមិនមែនតាមរយៈបុគ្គលទេ។ ការផ្លាស់ប្តូរនូវគំនិតខុសៗគ្នាផ្ទាល់ខ្លួន ដែលមកពីគោលទស្សនៈផ្សេងៗជាទូទៅអាចនាំឱ្យឆ្ពោះទៅរកសកម្មភាពដ៏ប្រសើរ។ ទាំងនេះ គឺជាទំនោរឆ្ពោះទៅ រកការប្រៀបធៀបនូវគំនិតយោបល់ និងគំនិតប្រឈមមុខផ្សេងៗ ដែលអនុញ្ញាត្តិឱ្យយើងពិនិត្យឡើងវិញនិងថ្លឹងថ្លែង ពិចារណារកជំរើសផ្សេងៗគ្នា។ ម្យ៉ាងវិញទៀត ការសំរេចចិត្តរួមគ្នា គឺជាលទ្ធផលនៃការព្រមព្រៀងគ្នារវាងសមាជិក ក្រុមទាំងអស់។

## ៤. គុណសម្បត្តិ និង គុណវិបត្តិនៃការធ្វើការងារជាក្រុម

### គុណសម្បត្តិ និង គុណវិបត្តនៃការធ្វើអាជីវកម្មរួមគ្នា

| ប្រភេទអាជីវកម្ម | គុណសម្បត្តិ | គុណវិបត្តិ |
|---|---|---|
| អាជីវកម្មជាលក្ខណៈបុគ្គល | -សេចក្តីសំរេចចិត្តអាចធ្វើបានឆាប់ ហើយងាយស្រួល និងឆ្លើយតបទៅនឹងតម្រូវការរបស់បុគ្គល<br>-ប្រាក់ចំណេញជារបស់បុគ្គល | - អាជីវកម្មជាលក្ខណៈបុគ្គលមានកំលាំងតិច<br>- ថ្លៃចំណាយខ្ពស់ជាង<br>- រាល់ការទទួលខុសត្រូវ និងបន្ទុកការងារ គឺជារបស់អាជីវករម្នាក់ៗ |
| អាជីវកម្មជាក្រុម | -អាចចែករំលែកបន្ទុកការងារគ្នា<br>-ធនធានអាចបញ្ចូលគ្នាបាន<br>-ពួកគេមានកំលាំង សំលេង និង ឥទ្ធិពលក្នុងការចរចារ<br>-សមាជិកអាចរៀនពីគ្នា<br>-គេអាចសន្សំលើការចំណាយ<br>-គេអាចចរចារដើម្បីបានតំលៃថោកជាងនៅពេលទិញវត្ថុធាតុដើមរួមគ្នា<br>-គេអាចផលិតបានច្រើន ហើយបំពេញតាមតំរូវការបញ្ជាទិញច្រើន<br>- ជំនួញធំ មានន័យថាប្រាក់ចំណេញច្រើន | -ការសំរេចចិត្តលើរឿងអ្វីៗចំណាយពេលយូរ ហើយមិនឆ្លើយតបនឹងតំរូវការរបស់មនុស្សផ្សេងៗគ្នា<br>-សមាជិកខ្លះ អាចឆ្លៀតឱកាសលើសមាជិកផ្សេងៗ<br>-វាមានការលំបាកក្នុងការធ្វើការធ្វើអាជីវកម្មរួមគ្នា បើសិនជាមិនមានការទុកចិត្តគ្នា រវាងសមាជិកក្នុងក្រុម |




## ៥. ការបែងចែកតួនាទី និង ភារកិច្ច របស់គណៈកម្មការក្រុម

### ក. គំរូរចនាសម្ព័ន្ធ និង តួនាទីរបស់ក្រុមការងារសហគមន៍មូលដ្ឋាន




### ខ. គំរូ តួនាទី និង ភារកិច្ច របស់ ក្រុមសហគមន៍មូលដ្ឋាន

## តួនាទីគណៈកម្មការគ្រប់គ្រងក្រុមផលិតស្រូវពូជ

**ប្រធានគណៈកម្មការគ្រប់គ្រងក្រុម**

- ដឹកនាំការកំណត់តម្រូវការ អាទិភាពសំរាប់រៀបចំផែនការផលិតកម្ម និងជំនួញ
- ពង្រឹងការអនុវត្តន៍បទបញ្ញាត្តិផ្ទៃក្នុង និង សេចក្តីសំរេចរបស់ក្រុម ដើម្បីធានាបាននូវដំណើរការរលូននៃប្រត្តិបត្តិការជំនួញ និងការគ្រប់គ្រង ដឹកនាំក្រុម
- ដើរតួនាទីជំនួសឱ្យក្រុម ការពារទ្រព្យសម្បត្តិ និងផលប្រយោជន៍ស្របច្បាប់របស់ក្រុម
- ទំនាក់ទំនង សម្របសម្រួលជាមួយស្ថាប័នពាក់ព័ន្ធ ដើម្បីស្វែងរកការគាំទ្របន្ថែម និងផ្សព្វផ្សាយព័ត៌មានថ្មីៗបន្តដល់ក្រុម
- រៀបចំ ចាត់ចែងកម្មវិធីប្រជុំជាប្រចាំ និងរាយការណ៍ពីភាពជឿនលឿននៃសកម្មភាពជំនួញរបស់ក្រុម
- សំរេចលើកិច្ចការរបរជំនួញរបស់ក្រុម ដើម្បីផលប្រយោជន៍របស់ក្រុម ដោយផ្អែកលើគោលដៅរួមរបស់ក្រុម
- ដោះស្រាយបញ្ហាកើតមានឡើងក្នុងក្រុម និង ចុះហត្ថលេខាលើសំណុំឯកសាររបស់ក្រុម
- ចូលរួមជួយដល់ក្រុមក្នុងដំណើរការទីផ្សាររបស់ក្រុម និង ការងារជំនួញផ្សេងៗទៀត របស់ក្រុម

**លេខា/អនុប្រធាន**

- ជាជំនួយដល់គណៈកម្មការក្នុងការងារកត់ត្រា កំណត់ហេតុអង្គប្រជុំ របាយការណ៍ដើម្បីដាក់ជូនក្រុម និងសន្និបាតសំរេច
- ជំនួយការដល់ប្រធានក្នុងការងារដឹកនាំក្រុមនៅពេលប្រធានអវត្តមាន និងផ្ទេរសិទ្ធិឱ្យ
- រៀបចំចាត់ចែងការងារប្រតិបត្តិការប្រចាំថ្ងៃរបស់ក្រុម

- ចូលរួមរៀបចំផែនការ ថវិកា របរជំនួញរបស់ក្រុម
- ថែរក្សារាល់សំណុំឯកសាររបស់ក្រុម និងរាយការណ៍ជូនអង្គប្រជុំ
- ចូលរួមជួយដល់ក្រុមក្នុងដំណើរការទីផ្សាររបស់ក្រុម និងការងារជំនួញផ្សេងៗទៀត របស់ក្រុម

## ហិរញ្ញិក / បេឡាករ

- ធ្វើបញ្ជីចំណូល ចំណាយរបស់ក្រុម
- ប្រមូលថវិកាជំនួញរបស់ក្រុម និង ពីភាគីផ្សេង ដែលមានទំនាក់ទំនងជំនួញជាមួយក្រុម
- រៀបចំបញ្ជីខ្ចី សង និងបញ្ជីគណនេយ្យជំនួញរបស់ក្រុម
- រាយការណ៍ចំណូល ចំណាយរបស់ក្រុមដល់ក្រុម
- ថែរក្សាឱ្យគង់វង់នូវទ្រព្យសម្បត្តិ ប្រាក់កាស់ ដែលក្រុមប្រគល់សិទ្ធិឱ្យរក្សាទុកដាក់
- គ្រប់គ្រងឱ្យមានសណ្តាប់ធ្នាប់ និងបានគង់វង់រាល់ឯកសារបញ្ជីស្នាមរបស់ក្រុម
- ចូលរួមជួយដល់ក្រុមក្នុងដំណើរការទីផ្សាររបស់ក្រុម និងការងារជំនួញផ្សេងៗទៀតរបស់ក្រុម

## សមាជិកទទួលបន្ទុកត្រួតពិនិត្យបច្ចេកទេសផលិត

- ជាជំនួយដល់ ក្រុមនិងគណៈកម្មការក្នុងការត្រួតពិនិត្យបច្ចេកទេសផលិតទៅតាមស្តង់ដាដែលបានកំនត់
- ជាជំនួយដល់ក្រុមក្នុងការរៀបចំផែនការផលិតកម្មរបស់ក្រុម
- ចុះត្រួតពិនិត្យ និងផ្តល់ការណែនាំទៅតាម បទដ្ឋានបច្ចេកទេសដែលក្រុមកំនត់
- ត្រួតពិនិត្យគុណភាពគ្រាប់ពូជដែលបានផលិតដែល លក់ចេញ និងទិញចូល
- រៀបចំកត់ត្រានូវរាល់ទិន្នន័យស្តុក និង លក់ចេញរបស់ក្រុម
- ចូលរួមជួយដល់ក្រុមក្នុងដំណើរការទីផ្សាររបស់ក្រុម និងការងារជំនួញផ្សេងៗទៀតរបស់ក្រុម

## សមាជិកទទួលបន្ទុកទីផ្សារ

- ជំនួសមុខឱ្យក្រុម ទំនាក់ទំនង ជាមួយអតិថិជនក្នុងការលក់ផលិតផល
- រៀបចំ និង រក្សារាល់ឯកសារ និងទិន្នន័យលក់របស់ក្រុមដើម្បីរាយការណ៍ជូនក្រុម
- ទទួលខុសត្រូវក្នុងការងារទីផ្សារ
- ជាជំនួយដល់ក្រុមក្នុងការរៀបចំផែនការផលិតកម្ម និងលក់ ហើយរាយការណ៍ជូន ក្រុម
- រៀបចំកត់ត្រានូវរាល់ទិន្នន័យស្តុក និង លក់ចេញរបស់ក្រុម
- ចូលរួមជួយដល់ក្រុមក្នុងដំណើរការទីផ្សាររបស់ក្រុម និងការងារជំនួញផ្សេងៗទៀតរបស់ក្រុម

=============

# មេរៀនទី២ ការប្រាស្រ័យទាក់ទង

## ១. ការប្រាស្រ័យទាក់ទងដែលមានប្រសិទ្ធភាព

ការប្រាស្រ័យទាក់ទង គឺជាការស្វែងយល់។ ការប្រាស្រ័យទាក់ទងនៅក្នុងអង្គការ និង ការទំនាក់ទំនងជាមួយដៃគូខាងក្រៅ ដែលមានប្រសិទ្ធភាព គឺជាកត្តាដ៏ចាំបាច់សំរាប់ភាពជោគជ័យនៅក្នុងក្រុម/សហគមន៍។

**ការប្រាស្រ័យទាក់ទង មានពីរប្រភេទ ៖**

**ការទំនាក់ទំនងផ្ទៃក្នុង:** ជាការទំនាក់ទំនងក្នុងក្រុម/សហគមន៍ ។ គ្រប់ផ្នែកនៃក្រុមអាជីវកម្ម អ្នកគ្រប់គ្រង បុគ្គលិក និងសមាជិក ត្រូវចែករំលែកនូវព័ត៌មាននឹងគ្នា ដើម្បីបង្កើតបានការយល់ដឹងរួមគ្នារបស់ក្រុមទាំងមូល ស្តីពី *គោលដៅ* ដែលក្រុមកំពុងបោះជំហានទៅ និង អ្វីដែលត្រូវអនុវត្ត ដើម្បីបានសំរេច *គោលដៅ* នោះ ។

**ទំនាក់ទំនងខាងក្រៅ:** ជាការធ្វើទំនាក់ទំនងទៅក្រៅក្រុម/សហគមន៍ ។ ក្រុមត្រូវការផ្សព្វផ្សាយពីទស្សនៈ និង សេវាកម្មរបស់ខ្លួន នៅក្នុងសង្គម និង សហគមន៍។ សំខាន់ជាងនេះទៅទៀត គេត្រូវផ្សព្វផ្សាយអំពីចំណាប់អារម្មណ៍រួម និង តំរូវការរបស់សមាជិកក្រុម ទៅដល់អ្នកពាក់ពន្ធ័សំខាន់ៗ ។

ការប្រាស្រ័យទាក់ទងមានធាតុ ២ សំខាន់ គឺ ការបញ្ជូន និង ការទទួល ។ វាជាដំណើរការ ដែលមានទិសដៅទៅមក សំរាប់ឱ្យអ្នកបញ្ជូន និង អ្នកទទួលសារ ធ្វើការជាមួយគ្នា ។ ការប្រាស្រ័យទាក់ទងល្អ កើតមានឡើង នៅពេលដែលអ្នកទទួល យល់បាននូវខ្លឹមសារទាំងស្រុង ។

→

| អ្នកបញ្ជូន | សារ | អ្នកទទួល |
|---|---|---|

←

➢ **អ្នកបញ្ជូនសារត្រូវ ៖**

- គិតអំពីអ្វី ដែលគេចង់ធ្វើការប្រាស្រ័យទាក់ទង
- បញ្ជូនខ្លឹមសារ ទៅតាមវិធីណាដែលច្បាស់ ងាយយល់
- ត្រួតពិនិត្យមើលថាតើអ្នកទទួលសារ បានយល់ច្បាស់(ពីសារដែលបានបញ្ជូន) ហើយឬនៅ
- កុំធ្វើការសន្និដ្ឋាន

➢ **អ្នកទទួលសារត្រូវ ៖**

- យកចិត្តទុកដាក់
- កុំប្រញាប់ធ្វើការសន្និដ្ឋាន
- សួរសំនួរ ដើម្បីបញ្ជាក់ទៅលើខ្លឹមសារ
- ត្រួតពិនិត្យមើលថាតើ បានយល់សារ(ដែលទទួលបាន) ទាំងស្រុងដែរឬទេ

ក្នុងដំណើរការប្រាស្រ័យទាក់ទង អ្នកទទួលសារ វិភាគសារដែលទទួលបាន ដោយផ្អែកលើទស្សនៈនិង បទពិសោធន៍ជីវិតរបស់ខ្លួន ដែលអាចខុសប្លែកពីទស្សនៈ និងបទពិសោធន៍ របស់អ្នកបញ្ជូនសារ ។ ដូច្នេះ អ្នកទាំងពីរ នេះត្រូវតែផ្តោតការយកចិត្តទុកដាក់ទៅលើការយល់ដឹងរួមគ្នា(ស្តីពីសារប្រាស្រ័យទាក់ទងគ្នានោះ)។ កាលណាអ្នកទទួលសារ បានយល់ដឹងអំពីអត្ថន័យរបស់សារបានកាន់តែច្បាស់ នោះទំនាស់ និងការយល់ច្រឡំ មានកាន់តែតិច ហើយ គោលបំណងនៃការប្រាស្រ័យទាក់ទង ក៏បានសំរេច ។

## ២. ឧបស័គ្គក្នុងការប្រាស្រ័យទាក់ទង

ទោះបីជាមនុស្សភាគច្រើនដឹងថា គេត្រូវការ ការប្រាស្រ័យដ៏ល្អនៅក្នុង ក្រុម/សហគមន៍អាជីវកម្មក៏ដោយ ក៏ជារឿយៗ វាមិនបានកើតឡើងបែបនេះឡើយ ។ នេះដោយសារ តែមានអ្វីមួយនៅបាំងផ្លូវ ដែលឱ្យឈ្មោះថាជា "**ឧបសគ្គ**" ហើយវាជាអ្នកដែលធ្វើមិនឱ្យសារ ឆ្លងកាត់បាន ។ អ្នកបញ្ជូនសារអាចគិតថា គេបានបញ្ជូនសាររួច ហើយ ប៉ុន្តែអ្នកទទួលសារមិនទាន់បានទទួលវាទេ ។




វាមានសារៈសំខាន់ក្នុងការយល់ដឹងអំពីឧបសគ្គ ដើម្បីឱ្យដឹងថានៅពេលដែលវាកើតឡើង យើងអាចដោះស្រាយបានប្រកបដោយប្រសិទ្ធភាព ។ បញ្ហាមួយចំនួន ដែលគេបានកំណត់ថាជាឧបសគ្គ នៅក្នុងការប្រាស្រ័យទាក់ទង មាន ៖

- ភាសា រួមទាំងភាសាប្រើតាមតំបន់ ដែលអ្នកមកពីក្រៅតំបន់ លំបាក ឬ មិនអាចយល់បាន ឬ យល់ខុស
- ឋានៈក្នុងសង្គម
- លំបាកចំពោះទីកន្លែង - សំលេងអ៊ូអរ
- ពេលវេលាមិនគ្រប់គ្រាន់
- បរិយាកាសមិនល្អ
- បញ្ហាយេនឌរ៍ (ការយល់ឃើញ/ឱ្យតំលៃពីឋានៈ តួនាទីស្ត្រី ឬ ឥរិយាបទសង្គម/សហគមន៍ មកលើស្ត្រី)
- វប្បធម៌ខុសគ្នា
- គោលបំណង និងការរំពឹងទុកខុសគ្នា
- ភាសាកាយវិការ
- ការរំខានផ្សេងៗ
- .....។ល។

ក្រៅអំពីបញ្ហាខាងលើនេះ នៅមានបញ្ហាផ្សេងៗទៀតទាក់ទងនឹងការស្តាប់ ដែលធ្វើឱ្យយើងទទួលសារមិនបានច្បាស់:

**ម្តងស្តាប់ម្តងឈប់:** មនុស្សភាគច្រើនគិតលឿនជាងនិយាយ ៤ ដង ។ នេះមានន័យថា អ្នកស្តាប់នៅសល់ពេល ៣/៤ ក្នុងមួយនាទី (ជាពេលទំនេរ) សំរាប់ការស្តាប់ ១នាទី ។ ជួនកាលអ្នកស្តាប់លែងស្តាប់ក្នុងពេល ៣/៤ នាទីនេះ ហើយ បែរជាគិតរឿងផ្សេងទៅវិញ ហើយខកខានមិនបានសង្កេតមើលព័ត៌មានតាមរយៈកាយវិការ និងពាក្យសំដី។ អ្នកស្តាប់ អាចបញ្ចៀសបញ្ហានេះបាន ដោយយកចិត្តទុកដាក់ទៅលើពាក្យពេជន៍ឱ្យបានច្រើន និងពិនិត្យមើលទៅលើភាសាកាយវិការ ដទៃទៀត (ដូចជា ការស្ទាក់ស្ទើរ និងកាយវិការដៃជើង ជាដើម) ។

**ពាក្យពេជន៍ដែលប៉ះពាល់ដល់អារម្មណ៍ ៖** សំរាប់អ្នកខ្លះ ពាក្យពេជន៍មួយចំនួនអាចធ្វើឱ្យមានប្រតិកម្មផ្លូវចិត្ត ។ នៅពេលស្តាប់ឮពាក្យទាំងនោះ (ដូចជា កុម្មុយនីស្ត សហករណ៍ អំពើពុករលួយ...) ពួកគេបាក់ទឹកចិត្ត ហើយឈប់ស្តាប់ ។ យើង លែងមានការទាក់ទងជាមួយអ្នកបញ្ជូនសារ ហើយបរាជ័យក្នុងការស្វែងយល់ ។ ជំហានដំបូងដើម្បីជំនះលើបញ្ហា នេះ គឺយើងត្រូវដឹងថា ពាក្យណាខ្លះដែលប៉ះពាល់អារម្មណ៍របស់យើងជាបុគ្គល ហើយព្យាយាមបន្តស្តាប់ដោយបើកចិត្តឱ្យទូលាយ នៅពេលដែលពាក្យទាំងនោះត្រូវបានគេប្រើ នោះ។

**ឆាប់ធ្វើការសន្និដ្ឋាន ៖** ជួនកាល យើងធ្វើការសំរេចភ្លាមៗថា ប្រធានបទដែលគេកំពុងនិយាយ មានលក្ខណៈគួរឱ្យធុញទ្រាន់ មិនពាក់ពន្ធ័ ឬក៏គ្មានន័យសម្រាប់យើង ហើយក៏ឈប់ស្តាប់ទៅ ។ ជារឿយៗ យើងធ្វើការសន្និដ្ឋានអំពីអ្វីដែលអ្នកនិយាយនឹងលើកឡើង ហើយនឹងបញ្ចប់បែបណានោះ ហើយក៏សំរេចមិនបាច់ស្តាប់ដល់ចុងបញ្ចប់ឡើយ ពីព្រោះយើងនឹងមិនបានដឹងអ្វីថ្មីឡើយ ។ វាជាការប្រសើរជាង បើសិនជាយើងបើកចិត្តឱ្យទូលាយស្តាប់ដើម្បីសិក្សាមើលថាតើវាជាការពិត ឬ អត់ ។

**ធ្វើពុតជាស្តាប់ ៖** ជួលកាលយើងមើលទៅហាក់បីជាយើងកំពុងស្តាប់ តែតាមការពិតយើងមិនបានស្តាប់ទេ ។ ផ្ទុយទៅវិញ យើងកំពុងតែស្រមៃអំពីអ្វីមួយផ្សេង ។ ទោះបីជាយើងខំសំលឹងមើលទៅអ្នកនិយាយ តែទឹកមុខរបស់យើងកំពុងតែស្រមៃអំពីរឿងផ្សេង អ្នកនិយាយ អាចដឹងថាយើងអត់ស្តាប់ទេ ។ បើសិនជាយើងដឹងថាយើងកំពុងយល់សុបិន្តទាំងពេលថ្ងៃ ឬក៏ បើអ្នកជាអ្នកបញ្ជូនសារ ហើយមើលឃើញថា អ្នកស្តាប់កំពុងតែធ្វើពុតជាស្តាប់ អ្នកគួរតែសំណូមពរឱ្យមានការសំរាក ឬ ផ្លាស់ប្តូរបរិយាកាស ។

**ពិបាកពេក មិនអាចចាប់បាន ៖** ជួនកាលយើងសំរេចចិត្តថាប្រធានបទពិបាកយល់ពេកសម្រាប់យើង ហើយយើងក៏ឈប់ស្តាប់ទៅ ។ នៅពេលដែលយើងស្តាប់រឿងអ្វីមួយ ដែលស្មុគស្មាញ យើងត្រូវតែខិតខំតាមដាន និងស្វែងយល់អំពីអ្វី ដែលគេកំពុងនិយាយ ។ បើយើងពិបាកយល់ អ្នកផ្សេងៗទៀតក៏ប្រហែលជាអញ្ចឹងដែរ ។ បើយើងនៅក្នុងក្រុមណាមួយ យើងអាចជួយអ្នកផ្សេង និងខ្លួនឯងបាន ដោយស្នើសុំឱ្យមានការបញ្ជាក់ឱ្យបានច្បាស់ ដោយមានឧទាហរណ៍ជាមួយផង ។

**ខ្ញុំមិនជឿ ៖** មនុស្សមិនចង់ឱ្យគេបដិសេធនូវអ្វី ដែលជាការពេញចិត្ត ទស្សនៈ និងភាពលំអៀងរបស់ខ្លួនទេ។ ដូចនេះនៅពេលដែលអ្នកនិយាយលើកឡើងពីអ្វីដែលប្រឆាំងនឹងគំនិត ឬ ជំនឿរបស់យើង យើងអាចឈប់ស្តាប់ ដោយមិនដឹងខ្លួន ឬក៏មានអារម្មណ៍ថា គេបញ្ឆោះឱ្យខ្លួន ហើយធ្វើផែនការប្រឆាំងតបត ។ ជំហានទី ១ ដើម្បីទប់ស្កាត់បញ្ហាបែបនេះ គឺត្រូវយល់ដឹងពីភាពលំអៀង និងទស្សនៈរបស់ខ្លួន ហើយដាក់វាទុកនៅមួយដុំ ទើបយើងអាចបើកចិត្តឱ្យទូលាយក្នុងការស្តាប់។ ពេលនោះយើងអាចយល់ខ្លឹមសារបានល្អប្រសើរ ហើយឆ្លើយតបយ៉ាងមានប្រសិទ្ធភាព ។

## ៣. វិធីធ្វើឱ្យការប្រាស្រ័យទាក់ទងកាន់តែប្រសើរឡើង

ជំនួយមួយចំនួនសម្រាប់ធ្វើឱ្យមធ្យោបាយទំនាក់ទំនងនៅក្នុងក្រុម/សហគមន៍ កាន់តែប្រសើរ ៖

- បែងចែកព្រឹត្តប័ត្រដែលមានព័ត៌មានសំខាន់ៗ ទៅឱ្យសមាជិកដោយផ្ទាល់
- បង្កើតប្រព័ន្ធមួយសម្រាប់ឱ្យសមាជិកដើម្បីបញ្ចេញយោបល់ ឬ កង្វល់របស់គេ ដើម្បីធ្វើឱ្យប្រតិបត្តិការអាជីវកម្មរបស់ក្រុម/សហគមន៍ កាន់តែមានភាពប្រសើរឡើង។
- ចែករំលែកព័ត៌មាន ជាពិសេសព័ត៌មានអំពីហិរញ្ញវត្ថុ ឱ្យបានទាន់ពេលទៅឱ្យសមាជិកគ្រប់ៗគ្នា
- រៀបចំកិច្ចប្រជុំខ្លីៗឱ្យបានទៀងទាត់
- នៅក្នុងកិច្ចប្រជុំទាំងនេះ ត្រូវធ្វើឱ្យប្រាកដថាសមាជិកម្នាក់ៗ យល់ពីកិច្ចពិភាក្សា ឯកភាព និងចូលរួមជួយខ្លះៗ ដើម្បីធ្វើឱ្យការទំនាក់ទំនងរវាងក្រុម/សហគមន៍ និងអ្នកខាងក្រៅ កាន់តែល្អប្រសើរឡើង
- បោះពុម្ពសៀវភៅតូច ដែលនិយាយយ៉ាងសង្ខេបអំពី ក្រុម/សហគមន៍ និងមានព័ត៌មានអំពីប្រយោគបេសកកម្ម គោលបំណង និង សេវាកម្មរបស់ក្រុម
- ប្រើប្រាស់ប្រពន្ធ័ផ្សព្វផ្សាយមួយចំនួនដូចជា កាសែត វិទ្យុ និងទូរទស្សន៍
- បោះពុម្ពផ្សព្វផ្សាយរបាយការណ៍សង្ខេបហិរញ្ញវត្ថុរបស់ក្រុម ជូនដល់អ្នកពាក់ពន្ធ័ដែលចាប់អារម្មណ៍
- ក្តាប់យកឱកាសក្នុងការកសាងទំនាក់ទំនងជាមួយអង្គការ ស្ថាប័ន្ន ផ្សេងៗ នៅពេលទៅចូលរួមប្រជុំ សិក្ខាសាលា និង ការតាំងពិពណ៌នានា ។

=============

# មេរៀនទី៣ ការរៀបចំអង្គប្រជុំ

## ១. និយមន័យ

ការប្រជុំ គឺនៅពេលណាដែលមនុស្សពីរ ឬ ច្រើននាក់ មកជួបជុំគ្នាដើម្បីផ្តល់ និងទទួលព័ត៌មាន ចែករំលែកគំនិតពិភាក្សា ពីបញ្ហានានាដែលប៉ះពាល់ដល់គេ ឬ ដើម្បីធ្វើការសំរេចចិត្ត។ អង្គប្រជុំ គឺជាផ្នែកដ៏សំខាន់មួយនៃការចូលរួមរបស់សមាជិក និងជាពិសេសសម្រាប់ការអនុវត្តន៍បែបលទ្ធិប្រជាធិបតេយ្យ។ យើងប្រើប្រាស់ពេលវេលាជាច្រើននៅក្នុងជីវិត ជាលក្ខណៈក្រុម/សហគមន៍អាជីវកម្ម។ ដូច្នេះជាការសំខាន់ គឺត្រូវប្រើពេលវេលាអង្គប្រជុំនេះឱ្យមានប្រយោជន៍បំផុត។

សមាជិកក្រុមចង់បានការប្រជុំមួយ ដែលមានគោលបំណងច្បាស់លាស់ និង លទ្ធផលក្នុងការសំរេចចិត្តច្បាស់លាស់។




## ២.ជំហានក្នុងការរៀបចំចាត់ចែងអង្គប្រជុំ

***ជំហានទី ១ ៖ ការរៀបចំអង្គប្រជុំ***

សកម្មភាពមួយចំនួន ដែលត្រូវរៀបចំ មុនបើកអង្គប្រជុំ រួមមាន ៖

- សំរេចអំពីគោលបំណងនៃកិច្ចប្រជុំ៖ តើការប្រជុំនេះរៀបចំដើម្បីផ្តល់ព័ត៌មានដល់សមាជិក? ឬ ជាការប្រមូលព័ត៌មាន? ឬក៏ ជាការពិភាក្សាពីបញ្ហាពិសេសអ្វីមួយ? ដើម្បីសំរេចថា តើត្រូវអនុវត្តសកម្មភាពប្រជុំយ៉ាងណា?
- បង្កើតគោលបំណងប្រជុំ ដែលមានលក្ខណៈ
  - ជាក់លាក់
  - អាចវាស់វែងបាន
  - អាចសំរេចបាន
  - ប្រាកដនិយម
  - កំណត់ពេលវេលាច្បាស់លាស់
- ជ្រើសរើសមនុស្សឱ្យត្រូវសម្រាប់ចូលរួមប្រជុំៈ អ្នកដែលមានចំណែកក្នុងការពិភាក្សា និងអ្នកដែលអាចទទួល និង បញ្ជូនព័ត៌មាន ទៅកាន់អ្នកដទៃបាន។
- តើពេលណាសមរម្យបំផុតសម្រាប់ស្ត្រី ក៏ដូចជា បុរស? តើទីកន្លែងណាដែលសមរម្យសម្រាប់ការប្រជុំអាចប្រារព្ធធ្វើទៅបានស្ងាត់ (មិនមានការរំខាន) និង មានសំភារៈឧបទ្ទេសជំនួយគ្រប់គ្រាន់។
- សំរេចថាអ្នកណានឹងដឹកនាំ ឬ ធ្វើជាប្រធានបទអង្គប្រជុំ ហើយអ្នកណាជាអ្នកសរសេរកំណត់ហេតុ។
- រៀបចំរបៀបវារៈសម្រាប់ការប្រជុំ ហើយបញ្ចូលប្រធានបទទាំងអស់សំរាប់ពិភាក្សា។
- រៀបចំធ្វើលិខិតអញ្ជើញ ដែលមានបញ្ជាក់ច្បាស់លាស់ពីគោលបំណងរបស់អង្គប្រជុំ ប្រធានបទដែលនឹងត្រូវពិភាក្សា ពេលវេលា និងទីកន្លែងប្រជុំ និង អ្វីដែលគេត្រូវយកជាប់មកជាមួយ។

### ជំហានទី ២ ៖ ការប្រព្រឹត្តិទៅនៃអង្គប្រជុំ

- ជ្រើសរើសអ្នកសម្របសម្រួល ដែលមានជំនាញ/បទពិសោធន៍ទំនាក់ទំនងល្អ និងស្តាប់បានល្អ។
- រៀបចំបន្ទប់ប្រជុំ ៖ រៀបកៅអីជារង្វង់មូល ដើម្បីបង្កលក្ខណៈងាយស្រួលដល់ការពិភាក្សាគ្នាដោយចំហ ហើយអាចឱ្យអ្នកផ្សេងទៀតមើលឃើញអ្នកនិយាយ ដោយមិនចាំបាច់ ងាកខ្លួនទេ។
- ធ្វើឱ្យប្រាកដប្រជាថាអ្នកសម្របសម្រួល និងអ្នកចូលរួមទាំងអស់ បានណែនាំខ្លួនឱ្យស្គាល់គ្នា
- បើកការពិភាក្សា និងផ្តល់នូវព័ត៌មានសំខាន់ៗ ដោយច្បាស់លាស់
- ពន្យល់ពីរបៀបវារៈ និងស្នើសុំការឯកភាពទៅលើប្រធានបទ និងលំដាប់លំដោយនៃការពិភាក្សា។
- បើចាំបាច់ មានរបាយការណ៍ប្រជុំលើកមុន ហើយស្នើសុំការឯកភាពលើរបៀវារៈអង្គប្រជុំនោះ។
- ណែនាំការពិភាក្សា និងធ្វើយ៉ាងណាឱ្យគ្រប់សមាជិកអង្គប្រជុំអាចចូលរួម ហើយគ្មាននរណាម្នាក់ដាក់សម្ពាធលើការពិភាក្សានោះឡើយ។
- ធានាថាមានការឯកភាពគ្នាលើលទ្ធផលប្រធានបទនីមួយៗ។ ព្យាយាមឈានឱ្យដល់ការសំរេចចិត្តដោយសម្លេងឯកច្ឆ័ន្ទ ឬ ដោយការបោះឆ្នោត។ តើត្រូវប្រមូលព័ត៌មានបន្ថែមដោយរបៀបណា ប្រសិនបើអ្នកចូលរួមមិនមានព័ត៌មានគ្រប់គ្រាន់សំរាប់ឈានទៅរកការសំរេចបានល្អ។



### ជំហានទី ៣ ៖ ការបញ្ចប់អង្គប្រជុំ

- ពិនិត្យការសំរេចចិត្តសំខាន់ៗឡើងវិញ ព្រមទាំងផែនការសកម្មភាពដើម្បីអនុវត្តការសំរេចចិត្តទាំងនោះ
- ចាត់ចែងមនុស្សឱ្យទទួលភារកិច្ច ដែលនឹងត្រូវអនុវត្ត ហើយរៀបចំពេលវេលា និងកំណត់ពេលការងារ
- ស្នើសុំចម្លើយតបអំពីការប្រជុំនោះ

### ជំហានទី ៤ ៖ របាយការណ៍ប្រជុំ

- រួមមាន ៖ ឈ្មោះរបស់អង្គភាព ដែលបានអញ្ជើញឱ្យចូលរួមប្រជុំ គោលបំណង ទីកន្លែង ថ្ងៃ ខែ ឆ្នាំ និងម៉ោងពេលប្រជុំ ហើយ និងបញ្ជីឈ្មោះអ្នកចូលរួម។

- រៀបរាប់ការសំរេចចិត្តផ្សេងៗដែលបានធ្វើ និងកត្តាសំខាន់ៗនៃការពិភាក្សាដែលនាំឱ្យមានការសំរេចនោះ។

============

# មេរៀនទី៤ ការសរសេររបាយការណ៍ និង កំណត់ហេតុ

## ១- របាយការណ៍

➢ **សេចក្តីផ្តើម:**

របាយការណ៍គឺជាផ្នែកមួយយ៉ាងសំខាន់ សំរាប់បង្ហាញពីសកម្មភាពដែលបានអនុវត្តកន្លងមក។ វាក៏អាចជាព័ត៌មានមួយ សម្រាប់ចែកចាយ ឬ ផ្សព្វផ្សាយឱ្យមជ្ឈដ្ឋាននានា បានដឹង ទាំងអ្នកខាងក្នុង និងក្រៅ។ ពិសេសជាងនេះទៅទៀត ជារបាយការណ៍សម្រាប់ផ្តល់ជូនអ្នកគ្រប់គ្រងរបស់យើងឱ្យដឹងអំពីលទ្ធផល ដើម្បីធ្វើការគាំទ្រ ក្នុងការអនុវត្តន៍ការងារបន្ត។ ការធ្វើសកម្មភាព ហើយគ្មានរបាយការណ៍ពីលទ្ធផល គឺយើងបានដឹងតែម្នាក់ឯង ដោយគ្មានអ្នកផ្សេងដឹង ប្រៀបដូចជាពាក្យមួយឃ្លា ថា " **ធ្វើការគ្មានរបាយការណ៍ ប្រៀបដូចជា យើងគ្មានធ្វើអ្វីទាំងអស់"** ។

ដើម្បីរៀបចំឱ្យបានជារបាយការណ៍មួយ យើងត្រូវចោទសួរថា យើងបានធ្វើអ្វី? នៅពេលណា? ហេតុអ្វីបានធ្វើ? ធ្វើជាមួយអ្នកណា? នៅកន្លែងណា? និង ធ្វើដោយរបៀបយ៉ាងដូចម្តេច?។

➢ **ជំហាននានាក្នុងការធ្វើរបាយការណ៍**

- ***សេចក្តីផ្តើម:*** ពិពណ៌នាសង្ខេបពីកិច្ចការដែលបានធ្វើ។ ដើម្បីសរសេរសេចក្តីផ្តើមបាន គឺត្រូវចោទសួរ ខ្លួនឯងនូវសំនួរបានធ្វើអ្វី? នៅទីណា? ពេលណា? ជាមួយអ្នកណា? និង ហេតុអ្វីបានជាធ្វើ ?។
- ***គោលបំណង ឬ ទិសដៅ:*** ចំណុចនេះត្រូវអធិប្បាយ អំពីមូលហេតុដែលធ្វើនេះ ឱ្យបានច្បាស់លាស់។
- ***វិធីសាស្រ្ត:*** ត្រូវពិពណ៌នាអំពី តើធ្វើកិច្ចការនេះដោយវិធីណា?។
- ***ទីកន្លែង:*** ត្រូវប្រាប់ពីទីកន្លែងដែលធ្វើ។
- ***កាលបរិច្ឆេទ:*** ត្រូវប្រាប់ពីថ្ងៃ ខែ ឆ្នាំ និង ម៉ោងពេលដែលធ្វើ ។
- ***អ្នកចូលរួម:*** ត្រូវប្រាប់អ្នកអានឱ្យដឹងថានរណាខ្លះ ដែលបានចូលរួមការធ្វើ
- ***លទ្ធផលនឹងផែនការ:*** ក្នុងរបាយការណ៍ ចំណុចនេះសំខាន់ណាស់ សំរាប់អ្នកអាន ព្រោះគេចង់ដឹងពីលទ្ធផលនៃសកម្មភាពដែលយើងបានបំពេញ ដែលអាចជា វិជ្ជមាន ឬ អវិជ្ជមាន។ នៅក្នុងនេះ ក៏ត្រូវបង្ហាញពីផែនការសកម្មភាព ដែលគ្រោងនឹងអនុវត្ត បន្ទាប់ពីទទួលលទ្ធផលពីការធ្វើកិច្ចការនេះ (អាចធ្វើជាតារាងភ្ជាប់ក្នុងឧបសម្ព័ន្ធ)។
- ***ផលវិបាក:*** ប្រសិនបើមានហេតុការអ្វី ដែលធ្វើឱ្យមានការរាំងស្ទះ បណ្តាលឱ្យប៉ះពាល់ដល់ គុណភាព នៃលទ្ធផលនោះ ត្រូវរាយការណ៍នៅទីនេះ។
- ***សំនូមពរ:*** តើអ្នកចង់ឱ្យអ្នកអាន ឬ អ្នកគ្រប់គ្រងជួយអ្វីខ្លះដល់យើង ដើម្បីធ្វើឱ្យផែនការសកម្មភាពនេះសំរេចលទ្ធផលបានល្អប្រសើរ។
- ***ឧបសម្ព័ន្ធ:*** ដើម្បីឱ្យរបាយការណ៍ កាន់តែមានសុក្រិតភាព ត្រូវមានឯកសារភ្ជាប់មកជាមួយផងដែរ ដូចជា: បញ្ជីឈ្មោះអ្នកចូលរួមដោយមានចុះហត្ថលេខា ឬ ស្នាមមេដៃ តារាងសង្ខេបលទ្ធផល (បើមាន) ឯកសារនានាដែលពាក់ព័ន្ធ រូបថតបើមាន...... ជាដើម។

## ២- កំណត់ហេតុប្រជុំ

### ➢ អ្វីទៅជាកំនត់ហេតុ

មានមតិជាច្រើនបានឱ្យនិយមន័យផ្សេងៗគ្នាទៅតាម ការយល់ឃើញ, បទពិសោធន៍ការងាររបស់គេរៀងៗខ្លួន ទៅលើពាក្យថា កំនត់ហេតុ, របៀបនៃការកត់ត្រា, ខ្លឹមសារដែលត្រូវកត់ត្រា, ... ជាដើម។ ប៉ុន្តែទោះបីជាមានការឱ្យនិយមន័យ ឬ ការរៀបចំ របៀបកត់ត្រាខុសគ្នាយ៉ាងណាក៏ដោយ ខ្លឹមសារជារួមគឺ " **ជាការកត់ត្រា នូវរាល់ខ្លឹមសារសំខាន់ៗ នៃអង្គប្រជុំមួយ ដើម្បីជាភស្តុតាង និងជារបាយការណ៍លំអិតសំរាប់ឱ្យអ្នកពាក់ព័ន្ធបាន ដឹងពីខ្លឹមសារ, លទ្ធផលនៃការប្រជុំ។** "

### ➢ ទម្រង់/ជំហាននៃការសរសេរកំនត់ហេតុ

ជារួមមានគំរូជាច្រើន ដែលត្រូវបានរៀបចំឡើងតំរូវទៅតាមការស្ថាប័ន ឬ អ្នកអានដែលជាអ្នកគ្រប់គ្រងនីមួយៗ។ ប៉ុន្តែ ជារួមសំខាន់បំផុតត្រូវចងចាំថា តើព័ត៌មានអ្វីខ្លះ ដែលត្រូវឱ្យអ្នកអានដឹង ដោយពុំបាច់មានអ្នកនៅរងចាំពន្យល់ បន្ថែមក្រោយពីអង្គប្រជុំត្រូវបានបញ្ចប់។ ជាទូទៅនៅក្នុងកំនត់ហេតុចែកចេញជា **បួនផ្នែកសំខាន់ៗគឺ**

- **សេចក្តីផ្តើម:** នៅក្នុងផ្នែកនេះជាទូទៅចាប់ផ្តើមចេញពី កាលបរិច្ឆេទនៃអង្គពិធី និង មូលហេតុនៃការប្រជុំព្រមជាមួយនិងអ្នកចូលរួម ដោយមានតួលេខសរុប ដែលត្រូវតែបញ្ជាក់ពីការប្រភេទអ្នកចូលរួម ដូចជា តួនាទី, ស្ត្រី បុរស... ជាដើម។
- **របៀបវារៈនៃការប្រជុំ:** របៀបវារៈនៃការប្រជុំត្រូវបានកត់ត្រាលំអិតព្រមជាមួយនឹងអ្នកទទួលខុស ត្រូវតាមរបៀបវារៈនីមួយៗផងដែរ។
- **លទ្ធផលប្រជុំ:** នៅក្នុងផ្នែកនេះ អ្នកកត់ត្រាត្រូវយកចិត្តទុកដាក់ទៅលើលទ្ធផលប្រជុំពិភាក្សាតាមរបៀបវារៈនីមួយៗ ដោយផ្តោតសំខាន់ទៅលើលទ្ធផលដែលបានឯកភាពគ្នា នឹងផែនការបន្ត បើមានជាជាងលើ ការជជែកលំអិតពេករបស់បុគ្គលនីមួយៗ។  នៅចុងបញ្ចប់ នៃផ្នែកលទ្ធផលនេះ អ្នកកត់ត្រាត្រូវបង្ហាញពីលទ្ធផលរួម ដែលបានឯកភាពគ្នាសំខាន់ៗ។
- **សេចក្តីបញ្ចប់:** នេះជាផ្នែកចុងក្រោយដែលជាទូទៅគឺ បង្ហាញពីបរិយាកាសនៃអង្គពិធី និង ពេលវេលាបញ្ចប់ រួមទាំងថ្ងៃ ខែ ឆ្នាំ ដោយមានការចុះហត្ថលេខា ប្រធានអង្គពិធី និង អ្នកកត់ត្រា។
- **ឯកសារភ្ជាប់:** នៅផ្នែកនេះ អ្នកកត់ត្រាត្រូវទទួលខុសត្រូវក្នុងការភ្ជាប់នូវបញ្ជីវត្តមានដែលមានឈ្មោះ និងហត្ថលេខា អ្នកចូលរួមទាំងអស់ ព្រមជាមួយឯកសារភ្ជាប់នានា បើមាន ដូចជា លិខិតបទដ្ឋានដែលបានបង្ហាញនៅក្នុងពិធី, ឯកសារផ្សេងៗទៀត.... ជាដើម។

**គំរូឯកសារ**

## កំណត់ហេតុប្រជុំក្រុមកសិករផលិតស្រូវពូជ

កាលពីថ្ងៃទី............ខែ..................ឆ្នាំ............ក្រុមកសិករផលិតស្រូវពូជ............... ................................ បានរៀបចំកិច្ចប្រជុំនៅភូមិ..............................ឃុំ.............................. ស្រុក................................ ..........ខេត្ត.............................................ដែលមានសមាជិកក្រុមចូលរួមចំនួន.........../..........នាក់ (សរុប/ស្រី)លើចំនួនសមាជិកសរុប.........../..........នាក់ (ភ្ជាប់បញ្ជីវត្តមាន) ។ ព្រមទាំងភ្ញៀវចូលរួមមាន៖

..................................................................................................................................

..................................................................................................................................

..................................................................................................................................

..................................................................................................................................

..................................................................................................................................

..................................................................................................................................

របៀបវារៈនៃការប្រជុំមាន៖

..................................................................................................................................

..................................................................................................................................

..................................................................................................................................

..................................................................................................................................

..................................................................................................................................

..................................................................................................................................

..................................................................................................................................

បន្ទាប់ពីបានពិភាក្សាផ្លាស់ប្តូរយោបល់គ្នាអស់រយៈពេល....................រួចមកអង្គប្រជុំធ្វើការសំរេចដូចខាងក្រោម៖

| សេចក្តីសម្រេច | សម្លេងគាំទ្រ |
|---|---|
| .................................................................................................... | ..................... |
| .................................................................................................... | ..................... |
| .................................................................................................... | ..................... |
| .................................................................................................... | ..................... |
| .................................................................................................... | ..................... |
| .................................................................................................... | ..................... |
| .................................................................................................... | ..................... |
| .................................................................................................... | ..................... |
| .................................................................................................... | ..................... |
| .................................................................................................... | ..................... |
| .................................................................................................... | ..................... |

| | |
|---|---|
| ............................................................................................................ | ...................... |
| ............................................................................................................ | ...................... |
| ............................................................................................................ | ...................... |
| ............................................................................................................ | ...................... |
| ............................................................................................................ | ...................... |
| ............................................................................................................ | ...................... |
| ............................................................................................................ | ...................... |
| ............................................................................................................ | ...................... |
| ............................................................................................................ | ...................... |
| ............................................................................................................ | ...................... |
| ............................................................................................................ | ...................... |
| ............................................................................................................ | ...................... |
| ............................................................................................................ | ...................... |
| ............................................................................................................ | ...................... |
| ............................................................................................................ | ...................... |
| ............................................................................................................ | ...................... |
| ............................................................................................................ | ...................... |
| ............................................................................................................ | ...................... |
| ............................................................................................................ | ...................... |
| ............................................................................................................ | ...................... |
| ............................................................................................................ | ...................... |
| ............................................................................................................ | ...................... |
| ............................................................................................................ | ...................... |
| ............................................................................................................ | ...................... |

កិច្ចប្រជុំបានបញ្ចប់នៅវេលាម៉ោង..............................................................................ក្នុងបរិយាកាស សាមគ្គីភាព និង យោគយល់គ្នា។

ធ្វើនៅ...................................ថ្ងៃទី..........ខែ........ឆ្នាំ ២០........

បានឃើញ និងឯកភាព                    រៀបចំដោយ

ប្រធានក្រុម

## បញ្ជីវត្តមានសមាជិកក្រុម

| ល.រ | ឈ្មោះ | ភេទ | តួនាទីក្រុម [1] | ហត្ថលេខា | ផ្សេងៗ |
|---|---|---|---|---|---|
| ១ | | | | | |
| ២ | | | | | |
| ៣ | | | | | |
| ៤ | | | | | |
| ៥ | | | | | |
| ៦ | | | | | |
| ៧ | | | | | |
| ៨ | | | | | |
| ៩ | | | | | |
| ១០ | | | | | |
| ១១ | | | | | |
| ១២ | | | | | |
| ១៣ | | | | | |
| ១៤ | | | | | |
| ១៥ | | | | | |
| ១៦ | | | | | |
| ១៧ | | | | | |
| ១៨ | | | | | |
| ១៩ | | | | | |
| ២០ | | | | | |

[1] ប្រើកូដសំគាល់: (១)=ប្រធាន / (២)=អនុប្រធាន / (៣)=លេខាធិការ / (៤)=សមាជិកក្រុម / (៥)=គណៈប្រឹក្សា/ភ្ញៀវ

# មេរៀនទី៥ ការគ្រប់គ្រង និង ភាពជាអ្នកដឹកនាំ

## ១. ការដឹកនាំជាអ្វី?

-ជាការពិពណ៌នាអំពីបុគ្គលិកលក្ខណៈ ឥទ្ធិពល អាកប្បកិរិយា អំណាច ការសំរេចគោលបំណង និងការអភិវឌ្ឍ ភាពទំនាក់ទំនងល្អ។

-ភាពជាអ្នកដឹកនាំ ត្រូវមាន ឥទ្ធិពល-អំណាច មកលើអ្នកដទៃដើម្បីប្រតិបត្តិការងារ

-បង្កើតចក្ខុវិស័យ ដែលជារូបភាពខាងក្នុងផ្លូវប្រាជ្ញា-ខួរក្បាល និង ការមើលឃើញអំពីអ្វីដែលជាការវិវឌ្ឍន៍ សំរាប់អនាគត និងការផ្លាស់ប្តូរ

-ជាអ្នកថែរក្សាសកម្មភាពរបស់អង្គការ(ក្រុម) ឱ្យមានជីវិតរស់នៅជានិរន្តភាព

## ២. មុខងារដឹកនាំ

-ជាការបង្ហាញឱ្យឃើញនូវសមត្ថភាពរបស់អ្នកគ្រប់គ្រង ដែលបានចូលរួមផ្ទាល់ក្នុងការជំរុញណែនាំ សកម្មភាព របស់អ្នកក្រោមបង្គាប់ ឱ្យប្រព្រឹត្តិតាមគោលដៅដែលបានកំនត់។

-ការដឹកនាំពាក់ព័ន្ធច្រើនទៅនឹងសីលធម៌ ស្មារតី វិន័យ របស់និយោជិកក្នុងការងារ

-អ្នកដឹកនាំ ត្រូវចេះប្រើល្បិចគ្រប់សិល្បវិធី ដើម្បីទាក់ទាញ និយោជិក(ឬ អ្នកក្រោមបង្គាប់)ឱ្យបំពេញការងារ

-ជាការទំនាក់ទំនងចូលរួមផ្ទាល់ជាមួយនិយោជិក បង្ហាត់បង្រៀនពួកគេ ស្តាប់ការកែតំរូវ ជំរុញទឹកចិត្តគេ ត្រួតពិនិត្យគេ ដើម្បីកុំឱ្យប្រាស់ចាកពីគោលដៅ ដែលបានកំនត់ក្នុងផែនការ។

## ៣. លក្ខណៈពិសេស និងជំនាញខ្លះដែលអ្នកដឹកនាំមាន

- សេចក្តីអង់អាច
- មានការភ្ញាក់រលឹក
- មានភាពស្មោះត្រង់
- មានទំនុកចិត្តលើខ្លួនឯង
- មានថាមពល
- មានចំណេះដឹង
- មានជំនាញនៃការគ្រប់គ្រង
- រាងកាយ
- មានអំណាចស្របច្បាប់
- មានអំណាចផ្តល់រង្វាន់
- មានអំណាចដាក់ទណ្ឌកម្ម
- មានអំណាចលើកសរសើរ
- មានអំណាចឯកទេស

## ៤. ការរៀបចំខ្លួនសំរាប់ភាពជាអ្នកដឹកនាំ

-សង្កត់ធ្ងន់លើការអនុវត្តន៍

-គិតគូរដល់សមាជិក

-មានភាពស្មោះត្រង់

-ជំរុញទឹកចិត្ត

-ការសសើរ និងការទទួលស្គាល់

-ផ្ទេរស្វ័យភាព

-បញ្ជាក់ឱ្យច្បាស់ពីមុខងារ

-កំនត់ឱ្យល្អ

-កម្មសិក្សានិងការហ្វឹកហ្វឺន

-ការផ្សព្វផ្សាយពត៌មាន

-រៀបចំប្រព័ន្ធផ្តល់រង្វាន់
-ចូលរួមក្នុងការសំរេចចិត្ត
-អ្នកតំណាង
-ទិទៀន និងទណ្ឌកម្ម
-ធ្វើផែនការ
-សំរបសំរួល
-គ្រប់គ្រងជំលោះ
-សំរបសំរួលការទំនាក់ទំនង

## ៣. អ្នកតំបាញ



ស្ត្រីមួយក្រុមសំរេចចិត្តបង្កើតក្រុមអ្នកតម្បាញ



អ្នកដឹកនាំក្រុមរៀបការជាមួយអ្នកផលិតអំបោះ



ការលក់រួមគ្នាទទួលបានប្រាក់ចំណេញច្រើនជាងពីមុន ហើយពួកគេមានសេចក្តីរីករាយណាស់



មានស្ត្រីម្នាក់មកប្រាប់ក្រុមនេះថាគាត់លក់ថ្លៃ ៦០០០/ម៉ែត្រ



ក្រុមចង់ទិញអំបោះពីស្ត្រីនោះ



តែអ្នកដឹកនាំ និងប្តីរបស់គាត់មិនយល់ស្រប



ជំលោះក៏បានកើតឡើងរវាងសមាជិកជាមួយអ្នកដឹកនាំនិងប្តីរបស់គាត់

## ៥. សារៈសំខាន់នៃភាពជាអ្នកដឹកនាំល្អ

ការដឹកនាំត្រូវបានគេឱ្យនិយមន័យថា ជាដំណើរការប្រើឥទ្ធិពលទៅលើមនុស្ស ដើម្បីជួយឱ្យការខិតខំរបស់ពួកគេឈានទៅសំរេចគោលដៅជាក់លាក់ ។

ការដឹកនាំនិងការគ្រប់គ្រង គឺជាការងារពីរផ្សេងគ្នា ៖

- ដឹកនាំ គឺជាការនៅពីមុខដើម្បីបង្ហាញផ្លូវ ដូចនេះអ្នកដឹកនាំ គឺអ្នកណែនាំ ឬ តម្រង់ទិសសំរាប់ក្រុម
- ការគ្រប់គ្រង គឺជាការទទួលខុសត្រូវចំពោះកិច្ចការនានារបស់ក្រុម/អង្គភាព ដូចនេះអ្នកគ្រប់គ្រង គឺជាអ្នកត្រួតពិនិត្យកិច្ចការនៅក្នុងក្រុម/អង្គភាព ។

ក្រុម/សហគមន៍អាជីវកម្មខ្លះមានទាំងអ្នកដឹកនាំ (ជាប្រធាន )និង អ្នកគ្រប់គ្រង (អគ្គលេខាធិការ) ដែលមានតួនាទីផ្សេងៗគ្នា ។ តែនៅក្នុង ក្រុម/សហគមន៍ខ្លះទៀត កិច្ចការទាំងពីរនេះត្រូវបានគេដាក់បញ្ចូលគ្នា ។ នេះមានន័យថាអ្នកដឹកនាំ ត្រូវតែមានជំនាញគ្រប់គ្រងឱ្យបានរឹងមាំដែរ ។

ភាពជោគជ័យរបស់ក្រុម/អង្គភាព/សហគមន៍ និងអង្គភាពអាជីព គឺ ពឹងផ្អែកលើអ្នកដឹកនាំ ។ អ្នកដឹកនាំដែលមានទំនាក់ទំនងល្អ និងស្មោះត្រង់ ធ្វើឱ្យសមាជិក មានការទុកចិត្តគ្នានៅក្នុងក្រុម/សហគមន៍របស់ពួកគេ ។

➢ **តើអ្នកដឹកនាំល្អ មានចរិតលក្ខណៈដូចម្តេចខ្លះ? អ្នកដឹកនាំល្អគួរ ៖**

- ដឹងរឿងលំអិតពីអង្គភាព ដោយរាប់ទាំងសេចក្តីត្រូវការ និងយោបល់ទាំងឡាយរបស់សមាជិក
- យល់ពីបរិយាកាសនយោបាយ សង្គម និងច្បាប់ ដែលប៉ះពាល់ដល់សមាជិក
- ស្វែងរក និងទទួលបានការគាំទ្រពីខាងក្រៅ ដែលអង្គភាពត្រូវការ
- ជាអ្នកនៅមុខមួយជំហាននៃព្រឹត្តិការណ៍ទាំងឡាយ ដោយមានផែនការល្អ ប៉ុន្តែធ្វើសកម្មភាពភ្លាមៗនៅពេលមានភាពបន្ទាន់ ។
- កសាងការឯកភាពជាផ្លូងមួយនៅក្នុងអង្គភាព ដោយបង្ហាញបញ្ជាក់ពីទស្សនៈវិស័យច្បាស់លាស់នៃអនាគតរបស់ខ្លួន។
- ជាអ្នកមានសមត្ថភាពដោះស្រាយបញ្ហានានា និងធ្វើការសម្រេច
- ធ្វើការទាក់ទងបានល្អ ហើយលើកទឹកចិត្តសមាជិក និងបុគ្គលិក
- ទទួលយកការតិទៀន និងរៀនសូត្រពីសមាជិក
- ជាអ្នកដែលសមាជិកងាយស្រួលធ្វើការទាក់ទងជាមួយ



- **ការគ្រប់គ្រងរាប់បញ្ចូលមុខងារដូចខាងក្រោម ៖**
  - **ការធ្វើសេចក្តីសម្រេច ៖** ការជ្រើសរើសសកម្មភាពមួយ ពីក្នុងចំណោមជំរើសជាច្រើន ។
  - **ការរៀបចំ ៖** ការរៀបចំរចនាសម្ព័ន្ធ និងការបែងចែកការងារ ។
  - **ការធ្វើផែនការ ៖** ការរំពឹងទុកសម្រាប់ពេលអនាគត និងការគិតអំពីលទ្ធភាពផ្សេងៗទៀត ។
  - **ការត្រួតពិនិត្យ ៖** ការវាស់វែងការងារ ធៀបនឹងកត្តាបង្ហាញជាក់ស្តែងទាំងឡាយ ។
  - **ការប្រាស្រ័យទាក់ទង ៖** ការបញ្ជូនគំនិត ព័ត៌មាន និងការណែនាំដោយមានប្រសិទ្ធភាព ។
  - ការតម្រង់ទិសដៅ ការណែនាំ និងត្រួតពិនិត្យអ្នកក្រោមបង្គាប់ ដើម្បីឆ្ពោះទៅរកគោលដៅរួម ។

## ៦. បែបបទផ្សេងៗនៅក្នុងការដឹកនាំ

ទោះបីជាអ្នកដឹកនាំម្នាក់ៗមានបែបបទផ្សេងៗគ្នា យើងអាចបង្ហាញភាពខុសប្លែកគ្នារវាងបែបបទដឹកនាំ

| | |
|---|---|
| ដឹកនាំផ្តាច់ការ ឬ ដឹកនាំទៅតាមឋានានុក្រម | ជាការដឹកនាំប្រើសិទ្ធិអំណាចផ្ទាល់ហើយបទបញ្ជាសាមញ្ញ សំរេចចិត្តដោយគ្មានការពិគ្រោះយោបល់ មានសិទ្ធបង្ខំឱ្យធ្វើតាម ប្រើការបំភិតបំភ័យ គំរាមគំហែង និងពិន័យ ដើម្បីសំរេចតាមវិធីរបស់គេ។ |
| ដឹកនាំតាមលទ្ធិប្រជាធិប្បតេយ្យ ឬ ដឹកនាំដោយយកចិត្តទុកដាក់សំខាន់ទៅលើមនុស្ស | ជាការដឹកនាំតាមការជំរុញឱ្យនិយោជិក(ឬ អ្នកការោមបង្គាប់) ចូលរួមពិភាក្សា និងមានទំនាក់ទំនងសេរី គិតពីអារម្មណ៍របស់និយោជិក ដែលចូលរួមក្នុងការធ្វើសេចក្តីសំរេចចិត្ត បង្ហាញនូវគំនិត ឱ្យសួរ បង្ហាញពីបញ្ហា និង ទទួលការផ្តល់យោបល់ហើយ ធ្វើការសំរេចចិត្ត។ |

ជាទូទៅ បែបបទដឹកនាំដោយយកចិត្តទុកដាក់សំខាន់ទៅលើមនុស្ស មានអត្ថប្រយោជន៍ជាច្រើន ។ វាជួយធ្វើឱ្យសមាជិក របស់សហគមន៍ មានអារម្មណ៍ថាក្រុម/សហគមន៍ ជារបស់គេ និង មានកំលាំងចិត្តក្នុងការចូលរួមនូវអ្វីដែលគេអាចធ្វើបាន ។ អ្នកដឹកនាំដែលប្រើប្រាស់បែបបទដឹកនាំទៅតាមឋានានុក្រម តែងតែបង្កើតបរិយាកាសមួយដែលធ្វើឱ្យមនុស្ស ធ្វើការទៅតាមការបញ្ជា ជាជាងការគិតគូរចំពោះខ្លួនឯង ។

អ្នកដឹកនាំដែលល្អ ជាអ្នកដឹកនាំដែលមានភាពបត់បែន និងចេះប្រើបែបបទដឹកនាំមួយណាដែលសមស្របទៅតាមស្ថានភាព។ **ឧទាហរណ៍** ដូចជានៅក្នុងស្ថានភាពបន្ទាន់ គេត្រូវផ្លាស់ប្តូរពីបែបបទដឹកនាំដោយយកចិត្តទុកដាក់សំខាន់ទៅលើមនុស្ស មកប្រើប្រាស់បែបបទដឹកនាំទៅតាមឋានានុក្រម វិញ ។

## ៧. បញ្ហាជាក់លាក់នៃភាពជាអ្នកដឹកនាំ

បទពិសោធន៍របស់ក្រុម/សហគមន៍អាជីពនៅក្នុងបណ្តាប្រទេសមួយចំនួនបង្ហាញថាៈ

- អ្នកដឹកនាំខ្លះបានក្លាយជាអ្នកមានអំណាចខ្លាំង ហើយបន្ទាប់មកអង្គភាពនេះ ត្រូវពឹងផ្អែកលើគាត់ ។ ការណ៍នេះ តម្រូវឱ្យមានការចែករំលែកការទទួលខុសត្រូវ និង លើកទឹកចិត្តចំពោះអ្នកដែលមានសក្តានុពលភាពជាអ្នកដឹកនាំ ។
- អង្គភាពខ្លះដែលមានសមាជិកភាពភាគច្រើនជាស្ត្រី មានបុរសជាអ្នកដឹកនាំ ។ អង្គភាពនោះគួរលើកទឹកចិត្ត ទាំងស្ត្រី និង បុរស ឆ្ពោះទៅរកការទទួលខុសត្រូវលើភាពជាអ្នកដឹកនាំ ហើយប្រសិនបើចាំបាច់ គួរតែសម្រួលពេលវេលាអង្គប្រជុំនានា ឱ្យតម្រូវតាមសេចក្តីត្រូវការរបស់ស្ត្រី ។

- មនុស្សដែលមានឥទ្ធិពល ដូចជាអ្នកដឹកនាំតាមប្រពៃណីនៅតាមមូលដ្ឋាន មិនចាំបាច់ក្លាយជាអ្នកដឹកនាំក្រុម/សហគមន៍ឡើយ ។ ពួកគេអាចដើរតួនាទីខាងការគាំទ្រសីលធម៌ និងសេចក្តីថ្លៃថ្នូរ និងត្រូវស្នើឱ្យចូលរួមនៅពេលណាដែលមានករណីវិបត្តិ ឬ ជាផ្នែកមួយនៃការធ្វើសេចក្តីសម្រេចជាផ្លូវការដ៏សំខាន់មួយ ។

ក្រុម/សហគមន៍អាជីវកម្មមួយគួរមានក្រុមអ្នកដឹកនាំ ដែលត្រូវបានចាត់តាំងឡើង និងមានការទទួលខុសត្រូវដោយ ឡែកៗពីគ្នា ដោយផ្អែកលើសមត្ថភាពនិងផលប្រយោជន៍បំពេញឱ្យគ្នាទៅវិញទៅមក ។ នៅប្រទេសកម្ពុជា អ្នកដែលបានទទួលការគោរពនៅក្នុងក្រុម/សហគមន៍ ហើយមានការប្តេជ្ញាចំពោះក្រុម/សហគមន៍ ជាញឹកញាប់ត្រូវជ្រើសតាំងជាអ្នកដឹកនាំ។ ជារឿយៗ មនុស្សប្រភេទនេះត្រូវបានជ្រើសរើសពីចំណោមអ្នកដឹកនាំ សហគ្រិនរដ្ឋការស៊ីវិល ដែលចូលនិវត្តន៍ ឬ អ្នកជំនាញការដែលមានបទពិសោធន៍ ។



ប្រធានក្រុមត្បាញកន្ទ្រក ស្នើឱ្យក្រុមទិញរ៉ឺម៉កម៉ូតូមួយសំរាប់ដឹកកន្ទ្រកទៅលក់



គាត់និយាយថា បងប្រុសរបស់គាត់អាចឱ្យខ្ចីលុយសិន ។ សមាជិកផ្សេងៗក៏យល់ស្របតាមសំណើរ



នៅពេលទិញរ៉ឺម៉កបានហើយ ប្រធាននិងបងប្រុសចាប់ផ្តើមមានផែនការថ្មី



ប្រធានក្រុមប្រាប់សមាជិកថា ចាប់ពីពេលនេះទៅ ពួកគេត្រូវបង់ថ្លៃថែទាំរ៉ឺម៉ក បន្ទាប់ពីពេលដឹកទៅលក់ម្តងៗ



សមាជិកចាប់ផ្តើមបង់ថ្លៃថែទាំ



ប្រធានក្រុម និងបងប្រុសសប្បាយចិត្តណាស់នឹងផែនការនេះណាស់



ប៉ុន្តែក្រោយមកសមាជិកបានដឹងថា ប្រធានមិនដែលបង់ថ្លៃថែទាំនេះទេ ។ ដំណោះក៏ចាប់ផ្តើម

# មេរៀនទី ៦ ការគ្រប់គ្រងហិរញ្ញវត្ថុរបស់ក្រុម

## ១. សារៈសំខាន់នៃការគ្រប់គ្រងហិរញ្ញវត្ថុល្អ

ការមានប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុដ៏ល្អមួយ មានសារៈសំខាន់ណាស់ សំរាប់ក្រុម/សហគមន៍ និងការធ្វើអាជីវកម្ម ។ ក្រុម/សហគមន៍អាជីវកម្ម ត្រូវផ្តល់ព័ត៌មានឱ្យបានច្បាស់លាស់ ទៅឱ្យសមាជិកខ្លួនអំពីការចំណាយផ្សេងៗដែលកើតមានឡើង និង ប្រាក់ចំណូលផ្សេង ។ ដូចនេះ គេត្រូវការវិធីសាស្ត្រសំរាប់ការកត់ត្រាដែលមានភាពសាមញ្ញមួយ ប៉ុន្តែមានប្រសិទ្ធភាព។

មូលហេតុដែលនាំឱ្យមានឱនភាព (ការចុះខ្សោយ) របស់ក្រុម/សហគមន៍មួយ គឺ ការមិនចុះសម្រុង ឬ ការមិនទុកចិត្តគ្នា ជុំវិញបញ្ហាហិរញ្ញវត្ថុ។ បើគ្មានប្រព័ន្ធហិរញ្ញវត្ថុមួយ ដែលមានតម្លាភាព ងាយយល់បាន និងអាចដំណើរការបាន ប្រធាន និង សមាជិក មិនអាចធ្វើ ការសំរេចចិត្តបានសមរម្យឡើយ។

**ចរិតលក្ខណៈរបស់ប្រព័ន្ធគណនេយ្យមួយដែលល្អ រួមមានៈ**

- ព័ត៌មានស្តីពីចំណូល និងចំណាយ គឺត្រូវបានប្រមូលក្នុងលក្ខណៈជាប្រព័ន្ធ។
- ការប្រមូលទិន្នន័យ ជានិច្ចកាល ត្រូវតែមានលក្ខណៈបច្ចុប្បន្នភាព។ រយៈពេលចន្លោះរវាងប្រតិបត្តិការដែលបានធ្វើឡើង និង ពេលវេលាដែលត្រូវកត់ត្រាក្នុងគណនី គឺត្រូវមានគម្លាតអប្បបរិមា(តិច)បំផុត។
- ព័ត៌មានត្រូវរៀបចំ និងផ្តល់ទៅឱ្យបុគ្គលិក (សមាជិក) ដែលពាក់ព័ន្ធនៅក្នុងក្រុម/អង្គភាព។
- មិនមានការចំណាយណាមួយ ត្រូវបានធ្វើឡើងឡើយ លើកលែងតែមានការព្យាករណ៍នៅក្នុងថវិកា ឬមានការ អនុញ្ញាតិនៅក្នុងច្បាប់របស់ក្រុម/សហគមន៍។
- រាល់ឯកសារ និង សៀវភៅគណនេយ្យ ត្រូវចាក់សោរទុកនៅពេលណា ដែលមិនមានការប្រើប្រាស់។
- រាល់ការចុះបញ្ជី គឺត្រូវសរសេរដោយទឹកខ្មៅ ហើយមិនត្រូវធ្វើការកោសលុបឡើយ។
- ប្រព័ន្ធគណនេយ្យត្រូវមានតម្លាភាព ហើយមានភាពងាយយល់សំរាប់សមាជិក និងអ្នកដឹកនាំ។
- ត្រូវមានរបាយការណ៍ហិរញ្ញវត្ថុសំខាន់ៗ សំរាប់ឱ្យសមាជិកពិនិត្យ។

ក្រុម/សហគមន៍អាជីវកម្ម ត្រូវមាននីតិវិធីច្បាស់លាស់ ដែលបញ្ជាក់ថា អ្នកណាអាចមានសិទ្ធសំរេចក្នុងការចំណាយ ។ ជាទូទៅ វាត្រូវមានហត្ថលេខាពីរនាក់ សំរាប់ការចំណាយនីមួយៗ ដើម្បីឱ្យមានតម្លាភាព។ ហិរញ្ញិក និង អ្នកកត់ត្រាចំណូលចំណាយ ជាទូទៅអាចមានសិទ្ធិសំរេចទៅលើការចំណាយតូចៗ។ រីឯការចំណាយធំៗ គួរត្រូវមានការសំរេចពីប្រធានក្រុម/សហគមន៍ និង ហិរញ្ញិក ។ ការចំណាយសំខាន់ៗ ត្រូវតែមានការយល់ព្រមពីគណៈកម្មការថ្នាក់ខ្ពស់។ ជារឿយៗ ធនាគារត្រូវការគំរូហត្ថលេខា របស់គណៈកម្មការ ដើម្បីឱ្យគេអាចផ្ទៀងផ្ទាត់មានការចុះហត្ថលេខាត្រឹមត្រូវលើប័ណ្ណឥណទាន។ បើសិនជាគណៈកម្មការថ្នាក់ខ្ពស់ លាឈប់ពីក្រុម/សហគមន៍ ឬ មានអ្នកមកជំនួស ក្រុម/សហគមន៍ត្រូវបញ្ជូនឈ្មោះ និង គំរូហត្ថលេខាថ្មី ទៅឱ្យធនាគារ។

## ២. ផែនការថវិកា

ផែនការថវិកា គឺជាផែនការហិរញ្ញវត្ថុ ដែលបង្ហាញនូវការសង្ឃឹមទុករបស់សហគមន៍ពីចំណូល និងចំណាយសម្រាប់រយៈពេលមួយ ដែលជាទូទៅគឺ សម្រាប់មួយឆ្នាំ។ វាឆ្លុះបញ្ចាំងពីផែនការសកម្មភាព រួមទាំងការគ្រោងចំណាយ និង ការប៉ាន់ប្រមាណចំណូល ដែលរំពឹងទុក ផ្អែកតាមចំណូលពីមុន ហើយនិងចំណូលព្យាករណ៍ពីសកម្មភាពថ្មីៗ។

**គំរូគម្រោងថវិកា ៖**

| ចំណាយ | ចំណូល |
|---|---|
| -ប្រាក់ខែ ..................................<br>-ការធ្វើដំណើរ ............................<br>-ថ្លៃឈ្នួលគ្រូបណ្តុះបណ្តាល ....................<br>-ថ្លៃឧបករណ៍សំភារៈផលិតកម្ម .................... | - ថ្លៃបញ្ជីសមាជិកភាព .............................<br>- ប្រាក់សប្បុទានផ្សេងៗ .............................<br>- ចំណូលមកពីការបណ្តុះបណ្តាល .................<br>- ចំណូលមកពីការការលក់ផលិតផល ................. |
| សរុប ៖ | សរុប ៖ |

## ៣. ការព្យាករណ៍អំពីលំហូរសាច់ប្រាក់

ក្រុម/សហគមន៍អាជីវកម្មដែលមានថវិកាចំណូល និង ចំណាយច្រើនគួរសម គួរធ្វើការព្យាករណ៍អំពីលំហូរសាច់ប្រាក់របស់ខ្លួនឱ្យបានទៀងទាត់ ដើម្បីឱ្យប្រាកដថា ក្រុម/សហគមន៍មានថវិកានៅក្នុងដៃ នៅពេលត្រូវការចំណាយ។ ការព្យាករណ៍អាចឱ្យក្រុម/សមាគមបានដឹង ថាតើនឹងមាន ចំណូលប៉ុន្មាន និង ចំណាយប៉ុន្មានសម្រាប់ខែបន្ទាប់ ។ គេក៏ដឹងថា តើក្រុម/សហគមន៍នឹងខ្វះខាតថវិកាប៉ុន្មាន? ហើយត្រូវចាត់វិធានការបង្ការយ៉ាងណា? ដូចជាការខ្ចីប្រាក់ពីក្រៅបន្ថែមជាដើម។

**ឧទាហរណ៍ផែនការលំហូរសាច់ប្រាក់មានដូចតទៅ ៖**

| ផែនការលំហូរសាច់ប្រាក់ | | | | | | |
|---|---|---|---|---|---|---|
| ខ្ទង់ចំណាយ ចំណូល | មករា | កុម្ភៈ | មិនា | មេសា | ឧសភា | មិថុនា |
| **ប្រាក់ចំណូល** | | | | | | |
| ថ្លៃសមាជិកភាព | ៣០០០០ | ៣៥០០០ | | | | |
| ចំណូលបានពីការលក់ | ១០០០០ | ៨០០០ | | | | |
| ការផ្តល់សេវាកម្ម | ៣០០០ | ៤០០០ | | | | |
| **សរុបចំណូល** | ៤៣០០០ | ៤៧០០០ | | | | |
| **ប្រាក់ចំណាយ** | | | | | | |
| បៀវត្សរ៍ | | | | | | |
| ថ្លៃជួល | | | | | | |
| សំភារៈ | | | | | | |

## ៤. សៀវភៅបេឡា និងសៀវភៅចំណូលចំណាយ

សៀវភៅបេឡា និងសៀវភៅចំណូលចំណាយ គឺបង្ហាញពីសាច់ប្រាក់ដែលបានទទួល និងការចំណាយដោយក្រុម/សហគមន៍ ។ សមតុល្យរបស់សៀវភៅបេឡា គឺបង្ហាញពីចំនួនសាច់ប្រាក់នៅក្នុងដៃ ។ សៀវភៅចំណូល និងចំណាយ គឺ បង្ហាញពីប្រភពសាច់ប្រាក់ដែលបានទទួល និង គោលបំណងសាច់ប្រាក់ដែលបានចំណាយ។

| កាលបរិច្ឆេទ | បរិយាយ | សាច់ប្រាក់ | | | សន្សំ | ការលក់ | ប្រាក់ខែ | សំភារៈការិ. | ការធ្វើដំណើរ |
|---|---|---|---|---|---|---|---|---|---|
| | | ចូល | ចេញ | សមតុល្យ | | | | | |
| | | | | | | | | | |
| | | | | | | | | | |

**កំនត់សំគាល់**

- **ចំណូលៈ** គឺជាប្រាក់ ឬ បំណុលទាំងឡាយណា ដែលត្រូវបង់ចូលមកក្នុងក្រុម/សហគមន៍
- **ចំណាយៈ** គឺជាប្រាក់ទាំងឡាយណាដែលបានចាយ ដោយសមាជិក ឬ គណៈកម្មការក្រុម/សហគមន៍ ទោះជាការចំណាយនោះសម្រាប់ ការងាររដ្ឋបាល ឬ សម្រាប់ធ្វើអាជីវកម្ម ក៏ដោយ
- **សមតុល្យៈ** គឺជាប្រាក់ដែលមានក្រោយទូទាត់រវាងចំណូល និង ចំណាយ មានន័យថា ចំណូល ដក ចំណាយ គឺជាសមតុល្យប្រាក់ មានក្នុងក្រុម/សហគមន៍

## ៥. របាយការណ៍ហិរញ្ញវត្ថុ

អ្នកដឹកនាំរបស់ក្រុម/សហគមន៍អាជីវកម្ម ត្រូវតែរាយការណ៍តាមកាលកំណត់ជូនដល់សមាជិកអំពីស្ថានភាពហិរញ្ញវត្ថុរបស់ក្រុម/សហគមន៍ ។ ព័ត៌មានត្រូវតែបង្ហាញក្នុងភាពច្បាស់លាស់ និងការទាក់ទងគ្នា ដើម្បីឱ្យសមាជិកមានលទ្ធភាពយល់ពីស្ថានភាពថវិការបស់ក្រុម/សហគមន៍ខ្លួន ។ ព័ត៌មានដែលធ្វើឱ្យមានការភាន់ច្រឡំ និងមិនត្រឹមត្រូវ អាចនាំឱ្យមានការមិនទុកចិត្តគ្នា ក្នុងចំណោមសមាជិកក្រុម។

វិធីមួយដើម្បីបង្ហាញលទ្ធផលហិរញ្ញវត្ថុសំរាប់រយៈពេលណាមួយជាក់លាក់ គឺ តាមរយៈ របាយការណ៍ប្រាក់ចំណេញ និងប្រាក់ខាត ឬ អាចហៅថា របាយការណ៍ចំណូល និងចំណាយ ដែលមានដូចខាងក្រោម ៖

| ចំណាយ | ចំណូល |
|---|---|
| ................................................................<br>................................................................ | ................................................................<br>.............................................................. |
| **សរុប ៖** | **សរុប ៖** |

**របាយការណ៍សមតុល្យ ៖**

របាយការណ៍សមតុល្យ គឺបង្ហាញពីស្ថានភាពហិរញ្ញវត្ថុរបស់ក្រុម/សហគមន៍អាជីវកម្ម នៅពេលណាមួយ។ វាបង្ហាញអំពីថវិកាក្នុងដៃ ចំនួនថវិកានៅក្នុងធនាគារ និងទ្រព្យសម្បត្តិទាំងអស់ ដែលក្រុម/សហគមន៍មាន ព្រមទាំងបំណុលដែលក្រុម/សហគមន៍នៅជំពាក់។ ទ្រព្យសម្បត្តិរបស់ក្រុម/សហគមន៍ ត្រូវបានគណនា ដោយបូកបញ្ចូលនូវអ្វីដែលក្រុម/សហគមន៍មាន និងដកចេញនូវអ្វី ដែលក្រុម/សហគមន៍ជាប់ជំពាក់។

**របាយការណ៍សមតុល្យ ៖**

| ទ្រព្យសម្បត្តិ | បំណុល |
|---|---|
| -សាច់ប្រាក់នៅក្នុងដៃ .............<br>-សាច់ប្រាក់នៅក្នុងធនាគារ .............<br>-កូនបំណុល និងប្រាក់បុរេដែលបានបង់ឱ្យ .........<br>-ថ្លៃសមាជិកភាព .......................<br>-ថ្លៃឈ្នួលដែលបានបង់មុន ..................<br>-ស្តុកវត្ថុធាតុដើម និង ទំនិញ .............<br>-ផលិតផលសម្រាប់លក់ .............<br>-អចលនទ្រព្យ .....................<br>-គ្រឿងឧបករណ៍ការិយាល័យ .................. | ម្ចាស់បំណុល ៖<br>-ចំណាយលើផ្ទៃថ្លៃអគ្គិសនី ៖ .......................<br>-កម្ចី ៖ ....................<br>-ដើមទុន ៖ ...............<br>ប្រាក់ដែលរកបាននៅឆ្នាំ .................. |
| សរុប ៖ | សរុប ៖ |

## ៦. នីតិវិធីសវនកម្ម

សវនកម្ម គឺជាអធិការកិច្ច (ការផ្ទៀងផ្ទាត់) លើគណនេយ្យរបស់អង្គភាព ។ សវនកម្ម រួមមាន ៖

- រៀបចំជាមួយហិរញ្ញិក ដើម្បីពិនិត្យរាល់សៀវភៅគណនេយ្យ និងបញ្ជីស្នាមនានា
- មើលឱ្យច្បាស់ថា តួលេខនៅក្នុងសៀវភៅបេឡាបានបូកសរុបត្រឹមត្រូវ ហើយគ្មានចំណាយណាមួយ ផ្ទុយនឹងច្បាប់ ឬ បទបញ្ជាផ្ទៃក្នុងរបស់ក្រុម/សហគមន៍
- ពិនិត្យមើលសាច់ប្រាក់នៅក្នុងដៃ
- ផ្ទៀងផ្ទាត់មើលវិក្កយប័ត្រ
- ផ្ទៀងផ្ទាត់មើលបញ្ជីចំណាយ ដោយធៀបនឹងប័ណ្ណចំណាយ។
- ប្រៀបធៀបសមតុល្យប្រាក់របស់ក្រុម/សហគមន៍នៅក្នុងធនាគារ ជាមួយនឹងចំនួនទឹកប្រាក់ ដែលបានកត់ត្រា នៅក្នុងសម្រង់គណនីធនាគារ។
- ពិនិត្យមើលបញ្ជីសារពើភ័ណ្ឌឧបករណ៍។
- ពិនិត្យ និងបញ្ជាក់លើតារាងតុល្យភាព។







**ចប់**

=============

# មេរៀនទី៧ មូលដ្ឋានគ្រឹះទីផ្សារ

## ១. ការងារទីផ្សារ

កាលណាសិក្សាពីទីផ្សារ យើងត្រូវផ្តោតទៅលើ អតិថិជន តំលៃ និង ការផ្សព្វផ្សាយ។

### ក. អតិថិជន

អតិថិជន គឺជាអ្នកដែលទិញទំនិញ ឬ សេវាកម្មរបស់អាជីវករ ។ គោលបំណងនៃការធ្វើអាជីវកម្ម គឺប្រាក់ចំណេញ ។ អាជីវករអាចរកប្រាក់ចំណេញបានពីអតិថិជន ។ ដូចនេះ អតិថិជនទាំងឡាយ គឺមានសារៈសំខាន់ណាស់ សំរាប់អាជីវកម្ម ។ អាជីវករតែងចាត់ទុកអតិថិជន ជាស្តេច ។

### ខ.តំលៃ

តំលៃក៏ជាផ្នែកមួយសំខាន់ដែរ ។ ប្រសិនបើអ្នកផ្តល់នូវអ្វីដែលអតិថិជនទាំងនោះត្រូវការពេញចិត្ត និងចង់បាន នៅក្នុងតំលៃមិនសមហេតុផលទេ ពួកគេនឹងទៅរកនៅកន្លែងផ្សេងទៀត ហើយគេនឹងមិនមករកយើងទៀតទេ។

### គ. ការផ្សព្វផ្សាយ

អតិថិជនដែលពេញចិត្តនឹងទំនិញ ឬ សេវារបស់យើង គឺ ពួកគេមកម្តងហើយ ម្តងទៀត ។ ពួកគេនឹងប្រាប់មិត្តភ័ក្រ និង មនុស្សដទៃទៀត អំពីអាជីវកម្មរបស់យើង មានន័យថា គេជួយផ្សព្វផ្សាយឱ្យយើង។ នៅពេលដែលអតិថិជន ពេញចិត្តកាន់តែច្រើន មានន័យថា ការលក់របស់យើង នឹងកើនឡើង ហើយប្រាក់ចំណេញ របស់យើងកាន់តែកើនឡើងដែរ។

## ២. ហេតុដូចម្តេចបានជាអតិថិជនទិញទំនិញ?

- អតិថិជនទាំងឡាយទិញទំនិញ ទិញផលិតផល និងសេវាកម្មនានា គឺដើម្បីបំពេញសេចក្តីត្រូវការរបស់គេ។ អតិថិជនម្នាក់ៗ មានការចង់បានខុសៗគ្នា។ ខ្លះត្រូវការ
    - អាហារ ពីព្រោះគេត្រូវការបរិភោគ។
    - កង់ ពីព្រោះគេត្រូវការដឹកជញ្ជូន។
    - សំលៀកបំពាក់ស្អាតៗ ពីព្រោះគេចង់ឱ្យមើលទៅ គេចាប់អារម្មណ៍ និង មានការទាក់ទាញ។
    - ទូរទស្សន៍ ឬ វិទ្យុសំរាប់ពត៌មាន និង ការកំសាន្ត ។
    - អាវអៀម ដើម្បីការពារសំលៀកបំពាក់របស់ពួកគេ ។
    - ការសិក្សាដើម្បីបង្កើនចំណេះវិជ្ជា និងដើម្បីចំណូលខ្ពស់។

## ៣. ការងារទីផ្សារ និងដៃគូប្រកួតប្រជែង

ដៃគូប្រកួតប្រជែង គឺ រវាងអាជីវកម្មកំពុងដំណើរការទាំងឡាយ ដែលផ្តល់ផលិតផល ឬ សេវាកម្មប្រហាក់ប្រហែលគ្នានឹងសេវាកម្ម ឬ ផលិតផលរបស់អ្នក ។ អ្នកត្រូវចេះរៀនសូត្រពីដៃគូប្រកួតប្រជែងរបស់អ្នក ។ ជាមួយនឹងចំណេះដឹងស្តីពីបែបបទអាជីវកម្មរបស់ពួកគេ អ្នកអាចយកមកវិភាគ និង រកវិធីជួយឱ្យអាជីវកម្មរបស់អ្នកបានជោគជ័យ។

## ៤. បង្គុំម៉ាឃីតធីង

ការសិក្សាយល់ដឹងពីបង្គុំម៉ាឃីតធីង មានសារៈសំខាន់ណាស់សម្រាប់គ្រប់អាជីវកម្ម ។ អាជីវករដែលរកស៊ីទទួលបានជោគជ័យ ច្រើនតែជាអ្នកដែលយល់ច្បាស់លាស់ និង អនុវត្តបានប្រសើរពីបង្គុំម៉ាឃីតធីង។

នៅពេលចាប់ផ្តើមអាជីវកម្ម យើងត្រូវតែគិតពី បង្គុំម៉ាឃីតធីង ឱ្យបានច្បាស់លាស់ ។ ការសំរេចចិត្តធ្វើអាជីវកម្ម ដែលទទួលបានជោគជ័យ គឺ អាស្រ័យលើការចេះវិភាគទៅលើការគ្រប់គ្រងបង្គុំម៉ាឃីតធីង។ បង្គុំម៉ាឃីតធីង មានសមាសភាគ៥ ដូចខាងក្រោម:

១-ផលិតផល ឬ សេវា
២-តំលៃ
៣-ទីតាំង (កន្លែងចែកចាយ)
៤-ការផ្សព្វផ្សាយ
៥ មនុស្ស/ អតិថិជន

បង្គុំម៉ាឃីតធីង ជាចំណុចដែលអ្នកគ្រប់គ្រងទីផ្សារ អាចត្រួតពិនិត្យបាន អាចកែសំរួលបាន អាចកែលំអបាន ដើម្បីបំពេញឱ្យត្រូវចិត្តអតិថជននៅក្នុងទីផ្សារគោលដៅ ។ ទីផ្សារគោលដៅ គឺជាអតិថិជន ដែលមានសក្តានុពលសម្រាប់ផលិតផលរបស់យើង។

គំនូសបំព្រួញបង្គុំសមាសធាតុម៉ាឃីតធីង (ការធ្វើទីផ្សារ) មានដូច ដ្យាក្រាមខាងក្រោម៖

បង្គុំសមាសធាតុម៉ាឃីតធីង (The Marketing Mix)




**១-ផលិតផល:** ផលិតផលអាចជាទំនិញ និងសេវា។

- **ទំនិញ គឺជាសំភារៈ** ឧបករណ៍ របស់ប្រើប្រាស់ ដែលបានផលិតឡើង ឬ បង្កើតឡើង ដើម្បីដោះស្រាយតំរូវការរបស់អតិថិជន បើនិយាយឱ្យខ្លី គឺសម្រាប់ អតិថិជនទិញ។
- **សេវាកម្ម គឺជាសកម្មភាពទាំងឡាយណា ដែលផ្តល់នូវអ្វីមួយ** ដើម្បីឆ្លើយតបនឹងតម្រូវការជាសាធារណៈ ដូចជា វិស័យទេសចរ ធនាគារ ការលក់ទំនិញ ដែលជាផ្នែកមួយនៃសេដ្ឋកិច្ចរបស់ប្រទេស ឬ ក្រុមហ៊ុនមួយ

**២- តំលៃ = តំលៃសំរេច = ថ្លៃលក់**

តំលៃសំរេច គឺជាតំលៃ ដែលបូកសរុបជាមួយខ្ទង់ប្រាក់ចំណេញរួច ឬ តំលៃប្រៀបធៀបជាមួយគូរប្រជែង។ តំលៃមិនមែនគិតត្រឹមតែតំលៃផលិតទេ តែត្រូវគិតទាំងការបញ្ចុះតំលៃ ការបង់ពន្ធ ការបង់ការប្រាក់ ចំណាយពលកម្ម និង ចំណាយផ្សេងៗ រួមទាំងការចំណាយទៅលើការផ្សព្វផ្សាយផងៗ

**៣-ទីតាំង**

ទីតាំង គឺជាកន្លែងសំរាប់ដាក់លក់ទំនិញ ឬ សម្រាប់ចែកចាយទំនិញ។ **ទីតាំងល្អ គឺទីតាំងដែលសមស្រប ជាមួយនឹងមុខអាជីវកម្ម។** ជាទូទៅ ទីតាំង ត្រូវស្អាត ទូលាយ មានខ្យល់អាកាសល្អ មានអនាម័យ មានកន្លែងចត រថយន្ត ម៉ូតូ ។ល។

**៤-ការផ្សព្វផ្សាយ**

ការផ្សព្វផ្សាយ គឺ ការឃោសនាផ្តល់ដំណឹង ទៅឱ្យអតិថិជនដែលមានសក្តានុពល ក្នុងការទិញទំនិញរបស់យើង ។ ការផ្សព្វផ្សាយធ្វើឱ្យតំលៃផលិតផលកើនឡើង ដូចនេះយើងត្រូវធ្វើការវិភាគឱ្យបានត្រឹមត្រូវ នៅពេលធ្វើការផ្សព្វផ្សាយ។ ការផ្សព្វផ្សាយនៅជនបទ អាចធ្វើតាមរយៈការនិយាយប្រាប់គ្នា ពីមាត់មួយទៅមាត់មួយ។

**តារាងសង្ខេបរបស់បង្គុំម៉ាឃើតធីង**

| ផលិតផល | តំលៃ | ទីតាំង | ការផ្សព្វផ្សាយ |
|---|---|---|---|
| ▪ មុខងារ<br>▪ រូបរាង<br>▪ គុណភាព<br>▪ អនាម័យ<br>▪ ការវេចខ្ចប់<br>▪ ផ្លាកសញ្ញា<br>▪ ការធានា<br>▪ សេវា/ការគាំទ្រ | ▪ មានតារាងតំលៃ<br>▪ មានការបញ្ចុះតំលៃ<br>▪ ការចុះតំលៃ<br>▪ ការឱ្យទិញជឿ<br>▪ តំលៃការផ្សព្វផ្សាយ | ▪ ច្រកអតិថិជន<br>▪ ចំនួនអតិថិជន<br>▪ ការគ្រប់ដណ្តប់ទីផ្សារ<br>▪ ទីតាំងសមស្រប<br>▪ មានបរិយាកាសល្អ<br>▪ មានជាសុខភាព<br>▪ កន្លែងចតម៉ូតូ កង់ | ▪ ការផ្សាយពាណិជ្ជកម្ម<br>▪ អ្នកលក់និយាយប្រាប់<br>▪ ទំនាក់ទំនងសាធារណៈ<br>▪ ប្រព័ន្ធផ្សព្វផ្សាយ<br>▪ និយាយតៗ គ្នា |

**៥. មនុស្ស**

P5 = មនុស្សដែលអាចជាអតិថិជន (ដែលត្រូវសិក្សាឱ្យដឹងពីតម្រូវការបច្ចុប្បន្ន ឬ និន្នាការតម្រូវការនាពេលអនាគត ដើម្បីអភិវឌ្ឍន៍/ បង្កើតផលិតផល ឬ សេវាថ្មី ឆ្លើយតបចំតម្រូវការ ដែលបានកំណត់រកឃើញនោះ។

=============

# មេរៀនទី៨ ការចាប់ផ្តើមអាជីវកម្ម

## ១. ប្រភេទអាជីវកម្មនៅជនបទ

នៅជនបទ មិនសូវមានអាជីវកម្មធំៗទេ ។ អាជីវកម្មតាមទីជនបទ ច្រើនតែមានទំនាក់ទំនងទៅនឹងកសិកម្ម និងការលក់ដូរ ។ ប្រភេទអាជីវកម្មនៅជនបទ មានដូចជា៖

- **អាជីវកម្មខ្នាតតូច**
  - ធ្វើតុទូកៅអី សិប្បកម្មតូចៗ បង្កើតកន្លែងកែច្នៃផលិតផលកសិកម្ម ឬ អនុផលព្រៃឈើ
  - លក់ចំណី អាហារ នំ
  - កាត់សក់ ជួសជុលម៉ូតូ ជួសជុលម៉ាញ៉េ ទូរទស្សន៍
  - ចិញ្ចឹមសត្វ គោ ក្របី មាន់ ទា
  - បង្កើតក្រុមភ្លេងប្រពៃណីយ
  - ផ្តល់សេវាដឹកជញ្ជូន
  - លក់ចាប់ហួយ
  - ទិញអេតចាយ
  - បោកគក់
  - ការផលិតស្រូវពូជលល
  - ……លៗល
- **អាជីវកម្មខ្នាតមធ្យម**
  - ការលក់ផលិតផលកសិកម្ម ដូចជា ជី ពូជដំណាំ
  - បញ្ចូលអាគុយ
  - បង្កើតកសិដ្ឋាន
  - ទិញផលិតផលស្តុកទុកលក់ ឬ ប្រមូលទិញយកទៅលក់ ដូចជាស្រូវ ផលិតផលកសិកម្មជាដើម
  - ចុងភៅ ធុងបាស់ ជួលរោងការ
  - ការប្រមូលទិញស្រូវ
  - ការបណ្តាក់ជី
  - ចងការប្រាក់
  - ……លៗល

## ២. ការធ្វើផែនការអាជីវកម្ម

ការធ្វើផែនការអាជីវកម្ម ត្រូវចាប់ផ្តើមពីចំណុចទី១ នៃវដ្ត អាជីវកម្ម។

### ២.១. ការជ្រើសរើសប្រភេទអាជីវកម្ម

ក្នុងការជ្រើសរើសប្រភេទអាជីវកម្ម ត្រូវគិតគូរពិចារណាលើចំណុចដូចខាងក្រោម៖

- សមត្ថភាព និងជំនាញដែលយើងមាន ព្រោះបើមានជំនាញពិត ទើបធ្វើទៅបានជោគជ័យ។
- មានធនធាន សមស្របសម្រាប់ការចាប់ផ្តើម។
- មានតំរូវការច្រើនពីអតិថិជន ដែលមានសក្តានុពលក្នុងការទិញ។
- មានឱកាសល្អសម្រាប់ការចាប់ផ្តើមការធ្វើអាជីវកម្ម។
- មានការគាំទ្រពីគ្រួសារ និង សហគមន៍ ។

## ២.២. ការសិក្សាពីបង្គុំម៉ាឃីតធីង

នៅពេលដែលយើងសំរេចចិត្ត ជ្រើសរើសប្រភេទអាជីវកម្មរួចហើយ យើងត្រូវសិក្សាឱ្យបានស៊ីជំរៅអំពីបង្គុំម៉ាឃីតធីង ដូចខាងក្រោម៖

**- អតិថិជន** -មានអតិថិជនណាខ្លះ ដែលត្រូវការផលិតផលរបស់យើង?
-តើអតិថិជននេះមានចំនួនប្រហែលប៉ុន្មាន? ចំនួននេះអាចកើនឡើង ឬ ថយចុះ?
-តើអតិថិជនទាំងនោះមានទំហំចំណាយ ត្រឹមកំរិតណា?
-តើមានអតិថិជននៅក្រៅតំបន់ ឬ នៅទីផ្សារផ្សេងៗទៀត ដែលត្រូវការទំនិញយើង។
-អតិថិជនទាំងនេះត្រូវការជាប្រចាំ ឬ ត្រូវការម្តងម្កាល។

**-ផលិតផល** -ត្រូវមានគុណភាពកំរិតណា? អាចរក្សាទុកបានប៉ុន្មានថ្ងៃ? អាចធានាគុណភាពរយៈពេលយូរប៉ុណ្ណា?
-ជាផលិតផលប្រភេទណា ដែលស្របនឹងស្ថានភាពជីវភាពរបស់អតិថិជន
-តើត្រូវការផលិតចំនួនប៉ុន្មាន? ត្រូវការវត្ថុធាតុដើមពីប្រភពណាខ្លះ? ងាយរក ឬ ពិបាករក?
-ចំនួនដើមទុនសំរាប់ការផលិតប្រចាំថ្ងៃ ។
-សោភ័ណ្ឌភាព ការវេចខ្ចប់ ការថែរក្សាអនាម័យ។
-សេវាបង្កប់ ឬ បន្ថែម (ដោយឥតគិតថ្លៃ ឬ ក្នុងតំលៃបញ្ចុះណាមួយ)

**-តំលៃ** -តើត្រូវលក់តំលៃណាមួយដែលស្របនឹងជីវភាពរបស់អតិថិជន?
-តើតំលៃនេះ អាចប្រកួតប្រជែងនឹងអ្នកដទៃ បានឬទេ?
-តើតំលៃណាមួយដែលយើងអាចរកស៊ីចំណេញ ហើយអតិថិជនអាចទទួលយកបាន ?

**-ការផ្សព្វផ្សាយ** -ផ្តល់ដំណឹង តាមមិត្តភ្ក័ក បងប្អូន។
-យកចិត្តអតិថិជនដែលពេញចិត្ត ឱ្យជួយផ្សព្វផ្សាយបន្តពីផលិតផល ឬ សេវា។

**-មនុស្ស/អតិថិជន:** មនុស្សដែលអាចជាអតិថិជន (ដែលត្រូវសិក្សាឱ្យដឹងពីតម្រូវការបច្ចុប្បន្ន ឬ និន្នាការតម្រូវការនាពេលអនាគត ដើម្បីអភិវឌ្ឍន៍/ បង្កើតផលិតផល ឬ សេវាថ្មី ឆ្លើយតបចំតម្រូវការ ដែលបានកំណត់រកឃើញនោះ។

## ៣. ការរៀបចំផែនការអាជីវកម្ម

### ៣.១-ការធ្វើផែនការថវិកា

### ក-តំរូវការសំភារៈ និង ចំណាយលើសំភារៈ

| លរ | ឈ្មោះសំភារៈ | ឯកតា | ចំនួន | តំលៃរាយ | តំលៃសរុប | ទិញនៅឯណា? |
|---|---|---|---|---|---|---|
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | សរុប | | | | | |

### ខ-ចំណាយសម្រាប់ដំណើរការរយៈពេល ១ ថ្ងៃ

| លរ | ឈ្មោះសំភារៈ | ឯកតា | ចំនួន | តំលៃរាយ | តំលៃសរុប | ទិញនៅឯណា? |
|---|---|---|---|---|---|---|
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | **សរុប** | | | | | |

-ចំណាយសម្រាប់ដំណើរការរយៈពេល ១០ ថ្ងៃ:

-ចំណាយសម្រាប់ដំណើរការរយៈពេល ៣០ ថ្ងៃ:

### គ-ការរៀបចំគម្រោងកម្មវិធី

ការរៀបចំគម្រោងកម្មវិធី គឺមានសារៈសំខាន់ណាស់ ព្រោះយើងត្រូវការដឹងពីចំនួនថវិកាដែលយើងត្រូវចំណាយ និង ការប៉ាន់ស្មានពីចំណូលដែលយើងអាចលក់បាន រួចគណនាពីប្រាក់ចំណេញ ។

### ឃ-ការស្វែងរកប្រភពទុន

ដើមទុនជាកត្តាសំខាន់មួយ ក្នុងការចាប់ផ្តើមអាជីវកម្ម។ នៅពេលយើងបូកសរុបពីទុនដែលត្រូវការសម្រាប់ចាប់ផ្តើមអាជីវកម្មរួចហើយ យើងត្រូវគិតគូពីប្រភពធនធាន។ ប្រភពធនធានដែលគួរយកមកធ្វើអាជីវកម្ម គួរតែៈ

១-ជាទុនដែលមានស្រេច ឬ ទុនដែលបានសន្សំទុក។

២-ជាទុនដែលបានមកពីការលក់ធនធាន ដែលអាចលក់បាន។

៣-ជាទុនដែលអាចខ្ចីបានពីបងប្អូន មិត្តភក្រ័ ដោយគ្មានការប្រាក់ ឬ ការប្រាក់តិចតួច។

៤-ជាទុនឥណទានរបស់ធនាគារភូមិ ។

៥-ទុនឥណទានពីធនាគារឯកជន ក្នុងករណីដែលមិនអាចរកទុនពីប្រភពខាងលើបាន។

ការប្រើប្រាស់ទុនពីប្រភពទី ៤ និងទី៥ ត្រូវតែមានការប្រុងប្រយត្ន័ ព្រោះជាទុនដែលមានការប្រាក់។

### ៣.២ ការធ្វើផែនការដំណើរការ (តារាងសកម្មភាព)

| លរ | សកម្មភាព | តារាងពេលវេលាក្នុងឆ្នាំ ........................................................ | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ខែ ១ | ខែ ២ | ខែ ៣ | ខែ ៤ | ខែ ៥ | ខែ ៦ | ខែ ៧ | ខែ ៨ | ខែ ៩ | ខែ ១០ | ខែ ១១ | ខែ ១២ |
| ១ | រៀបចំឈូសឆាយដី | | | | | | | | | | | | |
| ២ | សង់រោង | | | | | | | | | | | | |
| ៣ | ទិញសំភារៈផលិត | | | | | | | | | | | | |
| | | | | | | | | | | | | | |

## ៤- ការធ្វើប្រត្តិបត្តិការអាជីវកម្ម

- អនុវត្តតាមផែនការ ដែលបានគ្រោងទុក។
- កែលំអពីចំណុចខ្វះខាត ឬ បំពេញបន្ថែមនៅចំណុចដែលត្រូវការ ហើយមិនមានក្នុងផែនការ។
- ពិភាក្សាដោះស្រាយបញ្ហាជាមួយនឹងអ្នកមានពិសោធន៍ធ្វើអាជីវកម្ម នៅពេលជួបបញ្ហា។

## ៥- ការវាយតំលៃអាជីវកម្មដែលមាននិរន្តរភាព

-ត្រួតពិនិត្យ លើ ចំណូល ចំណាយ ចំណេញ

-ចំនួនកើនឡើង ឬ ថយចុះរបស់អតិថិជន

-ការប្រៀបធៀបជាមួយដៃគូប្រកួតប្រជែង ធ្វើការលៃលំអ បង្កំម៉ាឃីតធីង បើចាំបាច់។

-ការទទួលយកគំនិត យោបល់របស់អតិថិជន ដោយត្រូវកែលំអ បើជាមតិភាគច្រើន ឬ សមស្រប

-ការពិនិត្យលើទ្រព្យសម្បត្តិ ដែលបានប្រើកន្លងមក ការកាត់រំលោះថ្លៃទ្រព្យសម្បត្តិ។

-ប្រៀបធៀបលទ្ធផលដែលបានអនុវត្ត ជាមួយផែនការដែលបានគ្រោងទុក។

-ពិចារណាលើការពង្រីក(អាជីវកម្ម) ឬ រក្សានៅដដែល។

=============

# មេរៀនទី៩ ការគ្រប់គ្រងអាជីវកម្ម

ការគ្រប់គ្រង គឺជាកិច្ចការសំខាន់ណាស់ សំរាប់គ្រប់សកម្មភាព ។ ដោយឡែកការគ្រប់គ្រងអាជីវកម្មមានសារៈសំខាន់ជាងការគ្រប់គ្រងនានា ព្រោះបើយើងគ្រប់គ្រងមិនល្អ មុខរបររបស់យើង នឹងបរាជ័យ ហើយបើមុខរបរបរាជ័យ វានឹងផ្តល់ផលលំបាកច្រើនយ៉ាង ជាមិនខាន។ ការគ្រប់គ្រងអាជីវកម្មនៅជនបទ នឹងផ្តោតលើ៖

-ការគ្រប់គ្រងមុខរបរ (បង្គុំម៉ាឃីតធីង)

-ការគ្រប់គ្រងធនធានមនុស្ស

-ការគ្រប់គ្រងថវិកា

## ១. ការគ្រប់គ្រងមុខរបរ

ការគ្រប់គ្រងមុខរបរ គឺផ្តោតទៅលើការគ្រប់គ្រងបង្គុំម៉ាឃីតធីង មានន័យថាត្រូវយកចិត្តទុកដាក់ជាប្រចាំចំពោះ៖

- **ផលិតផល** ៖ តើមុខទំនិញ ឬសេវា មានភាពប្រសើរហើយឬនៅ? តើឆ្លើយតបនឹងតំរូវការអតិថិជនឬនៅ?
- **តំលៃ** ៖ តើសមរម្យឬទេ? ថ្លៃជាងគេ ឬ ថោកជាងគេ? តើអតិថិជនពេញចិត្តនឹងតំលៃនេះដែរឬទេ?
- **ការផ្សព្វផ្សាយ**៖ តើអតិថិជន ដឹងពីអាជីវកម្មរបស់យើងកំរិតណា? គាត់ពេញចិត្តនឹងសេវាយើងឬទេ?
- **អតិថិជន** ៖ តើអតិថិជនរបស់យើងមានចំនួនថយចុះ ឬ មានចំនួនកើនឡើង ឬ នៅដដែល?

ក្រៅពីនេះ យើងក៏ត្រូវពិនិត្យតាមដានពីសកម្មភាព និងការផ្លាស់ប្តូរ របស់គូរប្រកួតរបស់យើងដែរ តើគេមានការផ្លាស់ប្តូរ ឬ កែសំរួលការរកស៊ីរបស់គេដែរឬទេ? បើមានការប្រែប្រួល តើមានការប៉ះពាល់ដល់ការរកស៊ីរបស់យើងឬទេ? បើមានការប៉ះពាល់ដល់ការរកស៊ីរបស់យើង តើយើងត្រូវដោះស្រាយយ៉ាងដូចម្តេច?

## ២. ការគ្រប់គ្រងធនធានមនុស្ស

ការធ្វើផែនការអាជីវកម្មនៅជនបទ ច្រើនតែមានលក្ខណៈតូច ហើយច្រើនតែប្រើមនុស្សដែលជាសមាជិកក្នុងគ្រួសារ ។ ទោះជាយើងប្រើតែមនុស្សនៅក្នុងគ្រួសារក៏ដោយ នៅពេលយើងធ្វើអាជីវកម្មដែលមានទំនាក់ទំនងជាមួយអតិថិជន យើងត្រូវតែបំរើអតិថិជនរបស់យើង។

ជាទូទៅអ្នកធ្វើអាជីវកម្ម ឬ អ្នកដែលមានទំនាក់ទំនងជាមួយអតិថិជន ត្រូវតែ៖

- មានការអប់រំច្បាស់លាស់ ពិសេសផ្នែកសុជីវធម៌ សំដីគួរសម ទន់ភ្លន់ ទឹកមុខញញឹមជានិច្ច។
- មានជំនាញសមស្របតាមការងារ
- ស្គាល់ច្បាស់ ពីមុខការ មុខនាទីរបស់ខ្លួន
- មានសុខភាពល្អ និង មានសំលៀកបំពាក់សមរម្យ
- មានការលើកទឹកចិត្ត ច្បាស់លាស់

## ៣. ការគ្រប់គ្រងថវិកា

ក្នុងអាជីវកម្ម ការគ្រប់គ្រងថវិកាជាកិច្ចការសំខាន់ និងជាកត្តាជោគជ័យ ឬ បរាជ័យរបស់អាជីវករ ។ អាជីវករនៅជនបទច្រើនបរាជ័យ ដោយសារការគ្រប់គ្រងថវិកាមិនបានល្អ ជាអាទិ៍មានដូចជា៖

- ការចេះតែដកយកលុយចេញ
- ការកាន់លុយច្រើនគ្នា
- ការចំណាយមិនដឹងមុខ
- ការជំពាក់មិនបានកត់ត្រាត្រឹមត្រូវ
- ខ្វះការសន្សំសំចៃ ។ល។

### ៣.១-ការកត់ត្រាថវិកា

ប៉ុន្តែវាក៏ជាការពិបាកណាស់ សម្រាប់អាជីវករនៅជនបទ ធ្វើបញ្ជីគណនេយ្យឱ្យបានត្រឹមត្រូវ ។ តែដើម្បីការគ្រប់គ្រងយ៉ាងហោចណាស់ អាជីវករត្រូវធ្វើដូចខាងក្រោម៖

-មានអ្នកកាន់ លុយតែម្នាក់គត់
-ត្រូវកត់ត្រាអ្នកដែលជំពាក់
-កត់ត្រាចំណូល ចំណាយប្រចាំថ្ងៃ
-រាប់លុយទុកប្រចាំថ្ងៃ
-បូកសរុបថវិកា ប្រចាំខែ ប្រចាំឆ្នាំ ។

មានគំរូតារាងកត់ត្រាជាច្រើន ដែលអាជីវករ យកមកប្រើបាន ឬក៏ អាចកត់ត្រានៅក្នុងសៀវភៅ ក៏បាន។ តារាងកត់ត្រា អាចមានគំរូដូចខាងក្រោម៖

**បញ្ជីថវិកាចំណូលប្រចាំថ្ងៃ**

| ថ្ងៃទីខែឆ្នាំ | ចំណូល ប្រចាំថ្ងៃ | ចំនួន | សរុបចំណូល | សេចក្ដីផ្សេងៗ |
|---|---|---|---|---|
| | | | | |
| | | | | |
| | | | | |
| | | | | |
| | **សរុបប្រចាំខែ ឆ្នាំ.........** | | | |

**បញ្ជីថវិកាចំណាយប្រចាំថ្ងៃ**

| ថ្ងៃទីខែឆ្នាំ | ចំណាយ ប្រចាំថ្ងៃ | ចំនួន | សរុបចំណាយ | សេចក្ដីផ្សេងៗ |
|---|---|---|---|---|
| | | | | |
| | | | | |
| | | | | |
| | **សរុបប្រចាំខែ ឆ្នាំ......** | | | |

**បញ្ជីកត់ត្រាអ្នកជំពាក់**

| ថ្ងៃទីខែឆ្នាំ | ឈ្មោះ ប្តី ប្រពន្ធ | ចំនួនជំពាក់ | មូលហេតុជំពាក់ | ថ្ងៃសន្យាសង |
|---|---|---|---|---|
| | | | | |
| | | | | |
| | | | | |
| | | | | |
| | **សរុបប្រចាំខែ ឆ្នាំ.....** | | | |

**បញ្ជីកត់ត្រាប្រាក់ចំណូល ចំណាយ ចំណេញប្រចាំខែ**

| ថ្ងៃទីខែឆ្នាំ | របាយការណ៍ប្រចាំ | ចំនួនចំណូលសរុប | ចំនួនចំណាយសរុប | ប្រាក់ចំណេញ | សេចក្តីផ្សេងៗ |
|---|---|---|---|---|---|
| | ខែ មករា | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | **សរុបប្រចាំ ឆ្នាំ.......** | | | | |

### ៣.២-ថ្លៃដើមក្នុងដំណើរការអាជីវកម្ម

- រាល់អាជីវកម្មទាំងអស់ ត្រូវមានថ្លៃដើមពីរប្រភេទគឺៈ

  - **ថ្លៃដើមមិនប្រែប្រួលៈ** ជាថ្លៃដែលទិញ សំភារៈ ឧបករណ៍ សំរាប់ការធ្វើអាជីវកម្ម ។

    ឧ. ប្រាក់ខែជួលកម្មករ ជួលផ្ទះ ធ្វើរោង ទិញគ្រឿងម៉ាស៊ីន។

  - **ថ្លៃដើមប្រែប្រួលៈ** ជាថ្លៃដែលទិញសំភារៈមកផលិតប្រចាំថ្ងៃ ឧទាហរណ៍ វត្ថុធាតុដើម ពូជស្រូវ ជី..។ល។

- ថ្លៃដើមមិនប្រែប្រួល ត្រូវគិតរំលោះប្រចាំខែ (ឬ វដ្តផលិតកម្ម) ព្រោះឧបករណ៍ទាំងនោះវាមានអាយុកាលសម្រាប់ប្រើប្រាស់ ហើយវានឹងខូចនៅពេលណាមួយ ហើយយើងត្រូវទិញថ្មីមកជំនួស។

  **ឧទាហរណ៍ៈ** ធុងទឹកកក មួយ មានតំលៃ ១២០០០ រៀល ហើយមានអាយុកាលប្រើប្រាស់ ១ ឆ្នាំ។

  តំលៃរំលោះប្រចាំខែ របស់វា គឺ ១០០០ រៀល ក្នុង ១ ខែ។

### ៣.៣. ថ្លៃដើមអាជីវកម្មទូទៅ

មុខថ្លៃដើមអាជីវកម្មទូទៅ ត្រូវគិត រួមមាន៖

- ថ្លៃទិញវត្ថុធាតុដើម
- ថ្លៃជួលផ្ទះ ឬ ជួលកម្មករ
- ការផ្សព្វផ្សាយ
- ថ្លៃសងរំលោះសំភារៈសំរាប់ផលិត
- ថ្លៃពលកម្ម
- ថ្លៃដឹកជញ្ជូន

### ៣.៤. ការកំណត់ថ្លៃលក់

ថ្លៃលក់ = ថ្លៃដើម + ប្រាក់ចំណេញ។

ប៉ុន្តែមុននឹងកំណត់ថ្លៃលក់ យើងត្រូវផ្ទួរផ្ទងថ្លៃលក់របស់យើង ជាមួយនឹងថ្លៃលក់របស់គូប្រកួត ។ យើងអាចបន្ថយប្រាក់ចំណេញ ដែលយើងកំណត់ខ្លះ ប្រសិនបើថ្លៃលក់របស់យើង ថ្លៃជាងថ្លៃលក់របស់គូប្រជែង។

ការកំណត់ថ្លៃលក់ គឺត្រូវប្រែប្រួលទៅតាមតំលៃវត្ថុធាតុដើម និង ថ្លៃលក់របស់គូប្រជែង។ ក្នុងករណីខ្លះ តំលៃលក់មិនអាចបន្ថយបាន តែយើងអាចបន្ថយបរិមាណទំនិញបាន ។ ការធ្វើបែបនេះ គឺដើម្បីរក្សាភាពរស់រាន នៅក្នុងទីផ្សារ។

=============

# មេរៀនទី១០ ការលើកកំពស់អាជីវកម្ម

ដំណើរការទាំងអស់នៅក្នុងជីវភាពប្រចាំថ្ងៃ តែងមានការប្រែប្រួលផ្លាស់ប្តូរជាប្រចាំ ។ ដើម្បីទទួលបានជោគជ័យក្នុងជីវភាពរស់នៅ នៅក្នុងស្ថានភាពដែលមានការផ្លាស់ប្តូរនេះ ការធ្វើអាជីវកម្មរបស់យើង ក៏ត្រូវមានការផ្លាស់ប្តូរដែរ ។ ការផ្លាស់ប្តូររបស់អាជីវកម្ម អាចឈានទៅកាន់តែប្រសើរ ឬ ឈានទៅកាន់តែលំបាក និងចំណេញតិច។ ដូចនេះដើម្បី រក្សាអាជីវកម្មឱ្យមានដំណើរការល្អ យើងត្រូវតែមានផែនការលើកកំពស់អាជីវកម្មរបស់យើង។

## ១. កត្តាដែលនាំឱ្យមានការលើកកំពស់អាជីវកម្មម

ជាទូទៅយើងសង្កេតឃើញមានកត្តាធំៗ ៣ ដែលនាំអោយមានការលើកកំពស់អាជីវកម្មៈ

១-ចំនួនប្រាក់ចំណេញរបស់យើងថយចុះ

២-មានការប្រកួតប្រជែងខ្លាំង ពីដៃគូប្រកួតប្រជែង

៣-មានឱកាសពង្រីកអាជីវកម្ម និងបង្កើនប្រាក់ចំណូល

## ២. មូលហេតុដែលនាំឱ្យមានការលើកកំពស់អាជីវកម្ម

### ២.១-ចំនួនប្រាក់ចំណេញរបស់យើងថយចុះ

| | |
|---|---|
| -អតិថិជនរបស់យើងថយចុះ | -ខ្សោយទំនាក់ទំនងជាមួយអតិថិជន |
| -បំរើសេវាកម្ម មិនទាន់សភាពការណ៍ | -ទំនិញឡើងថ្លៃ |
| -ផលិតផលនៅតែដដែល | -ទីតាំងមិនសូវល្អ |
| -ការគ្រប់គ្រងធនធានមិនបានប្រសើរ | -តំលៃលក់ថោកពេក។ |

### ២.២-មានការប្រកួតប្រជែងខ្លាំងពីដៃគូប្រកួតប្រជែង

-សេវាកម្ម ផលិតផល របស់យើងមិនល្អដល់គេ

-ការទំនាក់ទំនងជាមួយអតិថិជនមិនបានប្រសើរ

-សំភារៈ គេមានភាពប្រសើរជាង

-តំលៃទំនិញគេថោកជាងយើង

-ការផ្សព្វផ្សាយរបស់គេ ល្អជាងយើង

### ២.៣-ពង្រីកអាជីវកម្ម និងបង្កើនប្រាក់ចំណូល

-មានឱកាសដាក់លក់ផលិតផលថ្មី និងចំនួនច្រើនជាងមុន

-តំរូវការអតិថិជនកើនឡើង

-មានសមត្ថភាព និងលទ្ធភាពកាន់តែប្រសើរ។

## ៣. ការធ្វើផែនការកែលំអ ឬ ការលើកកំពស់អាជីវកម្ម

ក្នុងចំណោមកត្តាទាំង ៣ កត្តាដែលធ្វើឱ្យយើងព្រួយបារម្ភ គឺកត្តាទី ១ និង ទី២។ ដើម្បីកែលំអការធ្វើអាជីវកម្មរបស់យើង យើងត្រូវធ្វើផែនការកែលំអ តាមកត្តានីមួយៗ។

**ក-ចំនួនប្រាក់ចំណេញរបស់យើងថយចុះ**

ដូចយើងរកឃើញខាងដើមហើយចំនួនប្រាក់ចំណេញថយចុះ បណ្តាលមកពី អតិថិជនរបស់យើងថយចុះ និង វត្ថុធាតុដើម ឬ ទំនិញឡើងថ្លៃ។ ដើម្បីកែលំអ យើងត្រូវធ្វើការវាយតំលៃចំណុចខ្លាំង និង ខ្សោយរបស់យើងលើ បង្គុំម៉ាឃីតធីង របស់យើង គឺ ផលិតផល តំលៃលក់ ទីកន្លែង ការផ្តល់សេវា និងការផ្សព្វផ្សាយ។
យើងត្រូវពិនិត្យមើលថា៖

- តើការទំនាក់ទំនងជាមួយអតិថិជន មានស្ថានភាពដូចម្តេច?
- តើការបំរើសេវាកម្មរបស់យើង ពេញចិត្តអតិថិជន ឬ ទេ?
- តើផលិតផលរបស់យើង នៅតែជាតំរូវការរបស់អតិថិជនឬទេ?
- តើយើងត្រូវកែលំអ ផលិតផលយើងយ៉ាងដូចម្តេច?
- តើទីតាំងលក់របស់យើង សមរម្យហើយឬនៅ?
- តើការគ្រប់គ្រងធនធានរបស់យើងបានប្រសើរ ឬទេ?
- តើតំលៃលក់របស់យើងថោកពេកឬ?
- តើយើងបានកែសំរួលអ្វីខ្លះតាមការផ្តល់យោបល់របស់អតិថិជន ហើយនៅមានអ្វីខ្លះមិនទាន់បានកែលំអ?

ក្រោយពីពិនិត្យឃើញចំណុចខ្សោយហើយ យើងត្រូវតែធ្វើផែនការកែប្រែឱ្យបានទាន់ពេល ដើម្បីលើកកំពស់ការរកស៊ីរបស់យើងឡើងវិញ ។ ក្នុងករណីដែលយើងចង់តំឡើងថ្លៃទំនិញរបស់យើង យើងត្រូវពន្យល់អតិថិជន យើងឱ្យបានច្បាស់ពីមូលហេតុ ដែលនាំឱ្យមានការឡើងថ្លៃ។

**ខ-មានការប្រកួតប្រជែងខ្លាំងពីដៃគូប្រកួតប្រជែង**

អាជីវកម្មតែងតែរងសម្ពាធពីបរិយាកាសខាងក្រៅ ពិសេសគឺ គូប្រជែង។ នៅពេលដែលចំនួនអតិថិជនយើងថយចុះ មានន័យថា យើងមិនអាចបំពេញតំរូវការរបស់គេបានល្អ ដូចនេះគេត្រូវទៅស្វែងរកការបំពេញតំរូវការរបស់គេ ពីកន្លែង (អ្នកលក់/អ្នកផ្គត់ផ្គង់) ផ្សេងទៀត។ នៅពេលនោះ យើងត្រូវសិក្សាពីចំណុចខ្សោយរបស់យើងដោយប្រៀបជាមួយនឹងគូប្រជែង ដោយផ្តោតលើ៖

- កែលំអ សេវាកម្ម ផលិតផល របស់យើងឱ្យបានប្រហាក់ប្រហែល ឬ ល្អលើគេ។
- បង្កើនការទំនាក់ទំនងជាមួយអតិថិជន ឱ្យបានប្រសើរជាងមុន ពិសេសផ្នែកសេវា។
- ពិនិត្យមើល សំភារៈឧបករណ៍ប្រើប្រាស់របស់យើង តើមានភាពទាក់ទាញឬទេ ហើយត្រូវកែលំអ បើចាំបាច់
- ពិនិត្យមើលតំលៃទំនិញ គុណភាព ការវេចខ្ចប់ បើខ្វះខាត ត្រូវធ្វើការកែលំអ។
- មួយវិញទៀតយើង ត្រូវបង្កើនចំនួនមុខទំនិញដែលអតិថិជនត្រូវការ និងសំណូមពរ។
- ប្រៀបធៀបការផ្សព្វផ្សាយរបស់យើង និងការផ្សព្វផ្សាយរបស់គេ ហើយបើមានការខ្វះខាត ត្រូវកែលំអ។

### គ-ពង្រីកអាជីវកម្ម និងបង្កើនប្រាក់ចំណូល

អាជីវករដែលមានជោគជ័យ គឺអាជីវករ ដែលចាប់ផ្តើមរកស៊ីពីតូចៗ ហើយក្រោយមករីកចំរើនកាន់តែធំឡើងៗ ហើយក្លាយជាមុខរបរ តកូនតចៅ។ ដូចនេះនៅពេលដែលអាជីវកម្មរបស់យើង មានជោគជ័យ យើងត្រូវតែសិក្សាពីជោគជ័យ និង ពង្រីកឱកាសរកស៊ីរបស់យើង។ មួយទៀត អាជីវកម្មដែលមានជោគជ័យ ច្រើនតែជាអាជីវកម្ម ដែលមានលក្ខណៈចំរុះ គឺថា ត្រូវរកស៊ីឱ្យបានច្រើនមុខរបរ ដែលមានទំនាក់ទំនងគ្នា។

ការពង្រីកអាជីវកម្ម ច្រើនតែផ្សាភ្ជាប់ទៅនឹងឱកាស ដែលផ្តល់ឱ្យ។ ឧទាហរណ៍:

-មានអតិថិជនកាន់តែច្រើន មកទិញផលិតផលរបស់យើង

-យើងមានឱកាសផលិត និងដាក់លក់ផលិតផលថ្មីៗ និងមានចំនួនច្រើនជាងមុន

-មានអ្នកទទួលទិញផលិតផលយើងច្រើន ។

មានឱកាសដូចខាងលើតែមួយមុខ មិនទាន់គ្រប់គ្រាន់ទេ ដើម្បីបង្កើនអាជីវកម្ម ។ យើងក៏ត្រូវសិក្សាផងដែរអំពីសមត្ថភាព និង លទ្ធភាពរបស់យើង ថាតើ ប្រសិនបើយើងពង្រីក តើយើងមានលទ្ធភាព និងសមត្ថភាពគ្រប់គ្រាន់ដើម្បីដំណើរការ ដែរឬទេ?

ដូចនេះមុនពេលពង្រីកអាជីវកម្ម យើងត្រូវធ្វើផែនការ និង សាកល្បងសិក្សាពីផែនការរបស់យើង។ ប្រសិនបើពិនិត្យថា ផែនការរបស់យើង អាចអនុវត្តបាន អាចគ្រប់គ្រងបាន អាចទទួលខុសត្រូវបាន នុះទើបយើងចាប់ផ្តើមដំណើរការ។



============

# មេរៀនទី១១ និរន្តរភាពនៃអាជីវកម្ម

និរន្តភាពនៃអាជីវកម្មមានន័យថា អាជីវកម្មនៅតែមានដំណើរការ និង ទទួលបានប្រាក់ចំណេញ។ អាជីវករទាំងអស់ សុទ្ធតែចង់ឱ្យអាជីវកម្មរបស់ខ្លួន មាននិរន្តភាព ។

## ១. កត្តាដែលនាំឱ្យអាជីវកម្មមាននិរន្តភាព

អាជីវកម្មមាននិរន្តភាព នៅពេលដែលៈ

- ផលិតផលរបស់យើងនៅតែមានទីផ្សារ (មានគេទិញ)
- អតិថិជននៅតែមានតំរូវការលើផលិតផលរបស់យើង
- ពុំទាន់មានផលិតផលណា អាចជំនួសផលិតផលរបស់យើងបាននៅឡើយទេ
- ការផ្គត់ផ្គង់របស់យើង សមស្រប/ឆ្លើយតប នឹងតំរូវការរបស់ទីផ្សារ
- តំលៃផលិតផលរបស់យើងនៅតែសមស្របនឹងជីវភាព(លទ្ធភាពអាចទិញ)របស់អតិថិជន

## ២. និរន្តភាពនៃអាជីវកម្ម

អាជីវកម្មមាននិរន្តភាពអាស្រ័យដោយកត្តាពីរសំខាន់គឺៈ កត្តាបរិយាកាសខាងក្នុង និង កត្តាបរិយាកាសខាងក្រៅ។

**- បរិយាកាសខាងក្នុង រួមមានៈ**

- ផលិតផល
- តំលៃផលិតផល
- ការផ្តល់សេវា
- ទីកន្លែងចែកចាយ

**- បរិយាកាសខាងក្រៅរួមមានៈ**

- តំរូវការរបស់អតិថិជន
- ស្ថានភាពប្រាក់ចំណូលអតិថិជន
- ស្ថានភាពគូប្រកួតប្រជែង
- កត្តាអនុគ្រោះផ្សេងៗ ។

ដើម្បីឱ្យមាននិរន្តភាព យើងត្រូវធ្វើការកែលំអ ឬ ផ្លាស់ប្តូរចំណុចនីមួយៗ ដែលបានលើកឡើងខាងលើ។

**ក. ផលិតផលៈ**

- តើអតិថិជននៅតែត្រូវការផលិតផលយើងទេ?
- តើយើងត្រូវកែលំអផលិតផលយ៉ាងណាដើម្បីឱ្យត្រូវនឹងទីផ្សារ (គុណភាព រូបរាង បរិមាណ ការវេចខ្ចប់ និងសោភ័ណ្ឌភាព) ។
- តើផលិតផលណាខ្លះ ដែលយើងត្រូវបង្កើតឡើងថ្មី និង បង្កើនបរិមាណ?

- តើផលិតផលយើង មានលក្ខណៈចំរុះ ហើយឬនៅ?

## ខ. តំលៃផលិតផល

- តើតំលៃសព្វថ្ងៃ អាចរក្សាស្ថានភាពចំណេញបានហើយឬទេ?
- តើតំលៃណាមួយ ដែលអតិថិជននៅតែអាចទិញបាន?
- បើធ្វើការចុះថ្លៃ តើចំនួនអ្នកទិញ នឹងកើនឡើងឬទេ?
- បើឡើងថ្លៃជាងនេះបន្តិច តើចំនួនអតិថិជន អាចចុះប៉ុន្មាន?

## គ. ការផ្តល់សេវាៈ

- តើអតិថិជនពេញចិត្តនឹងសេវាសព្វថ្ងៃរបស់យើង ដែរឬទេ?
- តើមានចំនុចណាខ្លះ ដែលយើងមិនទាន់ធ្វើការកែលំអ តាមសំណូមពររបស់អតិថិជន?
- សំភារៈ ឧបករណ៍ផលិតរបស់យើង មានលក្ខណៈទំនើបកម្មសមស្របហើយឬនៅ?

## ឃ. ទីកន្លែងចែកចាយៈ

- អតិថិជនអាចមកកន្លែងលក់របស់យើង តាមវិធីណា? ងាយស្រួលរកឃើញឬទេ?
- ទីតាំងលក់របស់យើង សមស្របតាមអតិថិជនឬទេ?
- ទីតាំង និងការតុបតែង មានការទាក់ទាញភ្ញៀវដែរឬទេ?
- តើត្រូវធ្វើយ៉ាងណា ដើម្បីឱ្យអតិថិជនមកកាន់តែច្រើន?

## ង. តំរូវការរបស់អតិថិជន និងទីផ្សារៈ

- តើអតិថិជននៅតែត្រូវការទិញទំនិញយើង កំរិតណា?
- តើផលិតផលរបស់យើង នាំទៅដល់ទីផ្សារណាខ្លះ?
- តើមានផលិតផលណាមួយ ដែលអាចជំនួសផលិតផលយើងបាន?
- តើមានលក្ខណៈពិសេសអ្វី ដែធ្វើឱ្យផលិតផលយើង នៅតែមានទីផ្សារ(មានគេទិញ)?

## ច. ស្ថានភាពប្រាក់ចំណូលអតិថិជន

- តើចំណូលរបស់អតិថិជនកើនឡើង ឬថយចុះ?
- តើត្រូវពិចារណាតំលៃផលិតផលយើងយ៉ាងណា ដើម្បីឱ្យសមស្របនឹងស្ថានភាពរបស់ពួកគេ?
- តើត្រូវផលិតផលិតផលបែបណា ឱ្យសមស្របនឹងស្ថានរបស់ពួកគេ?
- តើត្រូវផ្តល់សេវារបៀបណា ដល់ពួកគេ?

## ឆ. ស្ថានភាពគូប្រកួតប្រជែងៈ

- តើគូប្រកួតប្រជែងរបស់យើង បានធ្វើការកែលំអយ៉ាងដូចម្តេចខ្លះ?

- តើយើងអាចធ្វើការកែលំអ ដូចពួកគេដែរឬទេ?
- បើធ្វើការកែសំរួល តើអតិថិជនអាចទទួលយកបានឬទេ? តើយើងអាចចំណេញ ឬ ខាត?

## ឈ. កត្តាអនុគ្រោះផ្សេងៗ

កត្តាអនុគ្រោះផ្សេងៗ រួមមានផ្លូវគមនាគមន៍ ការដឹកជញ្ជូន ការបង់ពន្ធ កំណើនសេដ្ឋកិច្ច គ្រោះធម្មជាតិ ការធ្វើដំណើរឆ្លងកាត់...។ល។ កត្តាទាំងនេះ សុទ្ធតែមានឥទ្ធិពលដល់និរន្តរភាពរបស់អាជីវកម្មយើង ដែលយើងត្រូវតែពិនិត្យសិក្សាឱ្យបានល្អិតល្អន់ផងដែរ នៅពេលយើងធ្វើផែនការដើម្បីនិរន្តរភាពអាជីវកម្មរបស់យើង។

ដូចនេះ ដើម្បីឱ្យមាននិរន្តរភាព យើងត្រូវតែចេះផ្លាស់ប្តូរ កែលំអចំណុចដូចបានពិភាក្សាខាងលើ ។ ដើម្បីកែលំអបានជោគជ័យ យើងត្រូវវិភាគពីចំណុចខ្លាំង និងចំណុចខ្សោយរបស់យើង រួមទាំងឱកាស និង ឧបសគ្គ (ការគំរាមកំហែង) ក្នុងការរកស៊ីយ៉ាងតិច ៦ ខែម្តង ដើម្បីធ្វើផែនការកែលំអឱ្យអាជីវកម្មរបស់យើង មានដំណើរការល្អ ប្រកបដោយនិរន្តរភាព។

*ចូរចង់ចាំ ថាអាជីវកម្ម ត្រូវមាន*

ការចាប់ផ្តើម → ការកែលំអ → ការបង្កើន → និរន្តរភាព

=============

**សូមឱ្យការចាប់ផ្តើមអាជីវកម្មរបស់អ្នក**
**មាន ការរីកចំរើន និង ប្រកបដោយការតាំងចិត្ត**